"Cambodians are far too dependent on cash. The more Cambodians become familiar with electronic payment methods, the better," Mr. Perkins added.

FTB introduced prepaid Visa cards more than two years ago, but the bank's small network made it a challenge for the cards to go mainstream, said Dan Felsing, FTB's project director for CashCard Distribution and Mobile Payments.

**Continued to page 19**

# គម្រោងសាកល្បងផ្តល់សេវារថយន្តក្រុងទាក់ទាញអ្នកដំណើរ២០.០០០នាក់រយៈពេលពីរសប្តាហ៍ដំបូង

**ដោយ Sek Odom and Simon Henderson - February 18, 2014**

លោក ឡុង ឌីម៉ង់ អ្នកនាំពាក្យសាលារាជធានីភ្នំពេញបានឱ្យដឹងកាលពីម្សិលមិញថា អ្នកដំណើរប្រហែល២០.០០០នាក់បានធ្វើដំណើរតាមរយៈសេវាកម្មរថយន្តក្រុងមានកម្រិតក្នុងរាជធានីភ្នំពេញចាប់តាំងពីគម្រោងសាកល្បងដឹកជញ្ជូនសាធារណៈរយៈពេលមួយខែបានចាប់ផ្តើម កាលពីរយៈពេលពីរសប្តាហ៍មុនដែលនេះជាសញ្ញាដ៏ល្អសម្រាប់ការពង្រីកសេវាទូទាំងរាជធានីភ្នំពេញនៅពេលគម្រោងសាកល្បងនេះបញ្ចប់នៅថ្ងៃទី៤ ខែមីនា។

នេះជាលើកទី២ហើយ ដែលសាលារាជធានីបានសាកល្បងផ្តល់សេវារថយន្តក្រុងសាធារណៈ ក៏ប៉ុន្តែពេលនេះសេវានេះមានប្រជាប្រិយភាពជាងនៅក្នុងឆ្នាំ២០០១ ដែលពេលនោះការសាកល្បងសេវាដឹកជញ្ជូនរយៈពេលពីរខែត្រូវបានបោះបង់ចោលពាក់កណ្តាលទី ដោយសារមានតម្រូវការសាធារណៈតិចតួច។

លោក ឌីម៉ង់ បានឱ្យដឹងថា "រយៈពេលពីរសប្តាហ៍ក្នុងការសាកល្បងសេវារថយន្តក្រុងសាធារណៈយើងកត់សម្គាល់ឃើញថា មានអ្នកធ្វើដំណើរជាមធ្យម១ ។៦០០នាក់ទៅ១.៧០០នាក់ ហើយថ្ងៃខ្លះមានអ្នកដំណើរតាមមើលទៅច្រើនជាងថ្ងៃផ្សេងទៀត"។

បច្ចុប្បន្ននេះ រថយន្តក្រុងកំពុងប្រតិបត្តិការលើសមត្ថភាពដឹកជញ្ជូនជាមធ្យមប្រហែល៦០ភាគរយដែលជាសញ្ញាដ៏វិជ្ជមានសម្រាប់ពិចារណាឃើញថា សេវានេះបាន និងកំពុងតែប្រតិបត្តិការបានរយៈពេលតែពីរសប្តាហ៍ប៉ុណ្ណោះ ក៏ប៉ុន្តែចំនួននេះបង្ហាញពីភាពជោគជ័យដោយសារសាធារណជនកាន់តែយល់ដឹងអំពីប្រព័ន្ធរថយន្តក្រុងសាធារណៈ។

លោកបានមានប្រសាសន៍ថា "ប្រជាពលរដ្ឋកំពុងតែផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន ហើយវិលមកជិះរថយន្តក្រុងវិញ ហើយយើងរំពឹងថា ចំនួនអ្នកធ្វើដំណើរតាមរថយន្តក្រុងនឹងកើនឡើង៤០ភាគរយនៅពេលយើងបន្តផ្តល់សេវានេះ"។

សេចក្តីសម្រេចថា តើត្រូវបង្កើតសេវាដឹកជញ្ជូនសាធារណៈទូទាំងរាជធានី ឬយ៉ាងណានោះនឹងធ្វើឡើងនៅពេលក្រោយពេលគម្រោងសាកល្បងបច្ចុប្បន្នក្រោមការដឹកនាំរបស់ទីភ្នាក់ងារ

**តទៅទំព័រទី ១៩**

# Buses Attract 20,000 Passengers in Two Weeks

**By Sek Odom and Simon Henderson | February 18, 2014**

About 20,000 passengers have traveled on Phnom Penh's limited city bus service since a month-long public transport experiment began two weeks ago, which bodes well for a citywide expansion of the service once the trial ends on March 4, City Hall spokesman Long Dimanche said Monday.

This is the second time the city has tried out public buses, but they are proving more popular this time around than in 2001, when a two-month trial service was scrapped halfway through due to waning public demand.

"Two weeks into the public bus experiment, we are seeing on average 1,600 to 1,700 passengers per day, with some days predictably seeing more passengers than others," Mr. Dimanche said.

The buses are currently operating at about 60 percent capacity on average, Mr. Dimanche said, which is very positive considering they have been operating for only two weeks and the numbers show how successful the public bus system could be as public awareness grows.

"People are changing their behavior and coming on board the bus project, and we expect the number of passengers will grow by up to 40 percent when we continue the service," he said.

The decision on whether to introduce citywide public transport will be taken once the current trial, which was led by the Japanese International Cooperation Agency (JICA), comes to an end.

Mr. Dimanche said that up to nine companies are in the running for the contract to operate the new system, though he said he could not remember any of the companies' names.

JICA spokesman Egami Masahiko said that though he always expected the trial to be a success, promoting the buses among students-many of whom have been taking the bus to school and university-had helped the project go beyond his expectations.

"Younger people share information more easily over the Internet on social media, so it was always our plan to encourage students to use the service," he said.

The growing popularity of the buses is not all good news, however, as it means that City Hall and the company that wins the contract may have to upscale their original blueprints.

"A smaller system may be easier to implement but it needs to be carefully considered, because if there are a lot of passengers the service will not satisfy public demand," Mr. Masahiko said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី១៨ ខែកុម្ភៈឆ្នាំ២០១៤

# លោក ហ៊ុន សែន សរសើរកិច្ចខិតខំប្រឹងប្រែង របស់រដ្ឋាភិបាលក្នុងការធានាប្រក្រតីភាពក្នុងប្រទេស

ដោយ Khy Sovuthy - February 18, 2014

កាលពីម្សិលមិញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រើប្រាស់សុន្ទរកថានៅក្នុងពិធីប្រគល់សញ្ញាបត្រឱ្យនិស្សិតដែលទើបតែបញ្ចប់ការសិក្សាផ្នែករដ្ឋបាលសាធារណៈក្នុងរាជធានីភ្នំពេញ ដើម្បីលើកឡើងជាថ្មីម្តងទៀតថា លោកមានបញ្ហាបន្តិចបន្តួចក្នុងការគ្រប់គ្រងប្រទេស ខណៈដែលតំណាងរាស្ត្រគណបក្សប្រឆាំងកំពុងធ្វើពហិការមិនទទួលយកអាសនៈរបស់ខ្លួននៅក្នុងរដ្ឋសភា ។

ថ្លែងទៅកាន់និស្សិតមកពីសាលាភូមិន្ទរដ្ឋបាល លោក ហ៊ុន សែន បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់ធានាប្រក្រតីភាពក្នុងការដឹកនាំប្រទេស ដើម្បីជួយជំរុញឱ្យមានការកែទម្រង់ដូចអ្វីដែលលោកបានសន្យាក្រោយការបោះឆ្នោតកាលពីឆ្នាំមុន។

លោក ហ៊ុន សែន បានមានប្រសាសន៍ទៅកាន់អនាគតមន្ត្រីរាជការស៊ីវិលថា "ទី១ បន្តដំណើរជាធម្មតានៃស្ថាប័នរដ្ឋ ដូចដែលខ្ញុំបានបញ្ជាក់ប៉ុន្មានដងកន្លងមកហើយ។ ឥឡូវហ្នឹង វាជាធម្មតាហើយ។ កុំទៅខ្វល់ថា វាជាប់គាំង ឬមិនជាប់គាំង"។

ដើម្បីតវ៉ាប្រឆាំងនឹងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីឆ្នាំមុន តំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិបាន និងកំពុងធ្វើពហិការរដ្ឋសភាតាំងពីរដ្ឋសភាបានចាប់ផ្តើមដំណើរការក្នុងខែកញ្ញាឆ្នាំមុន។

ណបក្សប្រឆាំងបានរៀបចំមហាបាតុកម្មជាច្រើនលើកច្រើនសារនៅក្នុងរាជធានីភ្នំពេញ រហូតទាល់តែរាជរដ្ឋាភិបាលដាក់ចេញនូវប្រតិបត្តិការបង្ក្រាបដែលបណ្តាលឱ្យមានការបាត់បង់ជីវិតកាលពីដើមខែមុន។

ទំនងជាទាក់ទងទៅនឹងប្រតិបត្តិការបង្ក្រាបនោះកាលពីម្សិលមិញ លោក ហ៊ុន សែន បានសង្កត់ធ្ងន់ទៅលើគុណតម្លៃសម្រាប់រដ្ឋាភិបាលដែលរក្សាការគ្រប់គ្រងស្ថានភាពនៅតាមដងផ្លូវនានា។ គួររំឭកថា ប្រតិបត្តិការបង្ក្រាបនោះបានបណ្តាល

**តទៅទំព័រទី ១៩**

# Hun Sen Lauds Own Efforts to Ensure Normalcy in Cambodia

**By Khy Sovuthy | February 18, 2014**

Prime Minister Hun Sen used a speech at a ceremony for graduating public administration students in Phnom Penh on Monday to reiterate that he was having little trouble governing the country while opposition lawmakers-elect boycott their seats in the National Assembly.

Speaking to the students from the Royal School of Administration, Mr. Hun Sen stressed the importance of ensuring normalcy in the running of the state to help push through the reforms he promised after last year's election.

"First, [we must] continue with the normal processes of state institutions like I have clarified a few times already," Mr. Hun Sen told the future civil servants. "Now, they are normal—don't worry about there being a deadlock or no deadlock."

In protest of the official results of last year's national election, lawmakers-elect from the CNRP have been boycotting the National Assembly since it was convened in September. The party had organized a series of mass demonstrations in Phnom Penh until the government unleashed a lethal wave of suppression early last month.

In an apparent reference to the suppression, in which five protesters were shot dead and more than 60 others beaten, shot or jailed without trial, Mr. Hun Sen on Monday also emphasized the value of his government maintaining control of the streets.

**Continued to page 19**

**តមកពីទំព័រទី ១២**

## ក្រុមហ៊ុនវីង និងធនាគារពាណិជ្ជកម្ម...

សហប្រតិបត្តិការនេះនៅសណ្ឋាគារ កាំបូឌីយ៉ាណាថា "លទ្ធភាពទទួលបាន និងបញ្ចូលទឹកប្រាក់ក្នុងកាតនេះមិនមាននៅស្ថាប័នហិរញ្ញវត្ថុផ្សេងក្នុងប្រទេសកម្ពុជាទេ"។ នៅក្នុងកម្មវិធីសន្និសីទសារព័ត៌មានអ្នកសារព័ត៌មានត្រូវបានផ្តល់ឱ្យនូវវីហ្សាកាតបង់ប្រាក់មុនចំនួន២០ដុល្លារ ។

លោក ភើគីន បានមានប្រសាសន៍បន្ថែមទៀតថា "ប្រជាជនខ្មែរពឹងផ្អែកយ៉ាងខ្លាំងទៅលើសាច់ប្រាក់។ នៅពេលមានប្រជាជនខ្មែរកាន់តែច្រើនមានការយល់ដឹងអំពីវិធីទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក វាជារឿងកាន់តែប្រសើរ"។

ធនាគារ FTB បានណែនាំឱ្យប្រជាជនប្រើប្រាស់វីហ្សាកាតបង់ប្រាក់មុនកាលពីជាងពីរឆ្នាំមុន ក៏ប៉ុន្តែដោយសារតែធនាគារនេះមានបណ្តាញប្រើប្រាស់ ទើបកាតនេះជួបបញ្ហាលំបាកក្នុងការផ្តល់សេវាកម្មនេះ បើតាមសម្តីរបស់លោក ដាន់ ហ្វេលស៊ីង (Dan Felsing) នាយកគម្រោងធនាគារ FTB ទទួលបន្ទុកផ្នែកចែកចាយ Cash Card និងទូទាត់ប្រាក់តាមទូរស័ព្ទដៃ។ លោកបានមានប្រសាសន៍ថា "កាលនោះមិនមានភាពរីកចម្រើនទេ"។

លោក ហ្វេលស៊ីង បានមានប្រសាសន៍ទាក់ទងទៅនឹងមូលហេតុដែលបណ្តាលឱ្យមិនមានភាពរីកចម្រើននេះថា "មិនមែនដោយសារតែវាមិនមែនជាផលិតផលល្អនោះទេ គឺដោយសារតែគ្មានគេដឹងអំពីវា"។

លោកនាយកគម្រោងរូបនេះបានលើកឡើងឱ្យដឹងបន្ថែមទៀតថា ការបង្កើតបណ្តាញចែកចាយរបស់ក្រុមហ៊ុន វីង អាចនឹងត្រូវការចំណាយប្រាក់ជាច្រើនលានដុល្លារ។ ធ្វើបែបនេះទើបមានប្រជាជនកាន់តែច្រើនថែមទៀត មានកាតនេះ"។

លោក ហ្វេលស៊ីង បានឱ្យដឹងបន្តទៀតថា ធនាគារ FTB មានកន្លែងទូទាត់ប្រាក់៤២កន្លែងដែលទទួលយកវីហ្សាកាតបង់ប្រាក់មុនរបស់ខ្លួនក៏ ប៉ុន្តែឥឡូវនេះក្រោមកិច្ចសហការជាមួយក្រុមហ៊ុន វីង មានជាង១.០០០កន្លែង។

លោក ភើគីន បានឱ្យដឹងទៀតថា ក្រុមហ៊ុនវីង មានគម្រោងបង្កើនចំនួនកន្លែងទូទាត់ឱ្យកើនឡើងដល់២.០០០កន្លែងក្នុងរយៈពេលពីរខែខាងមុខ។

ប្រធាននាយកប្រតិបត្តិធនាគារនានាបានលើកឡើងកាលពីម្សិលមិញថា ស្ថានភាពនៅតែត្រូវការការរង់ចាំមើលថា តើប្រជាជនខ្មែរនឹងជ្រើសរើសយកវីហ្សាកាតបង់ប្រាក់មុន ឬក៏អត់ ដោយសារភាគច្រើនក្នុងចំណោមប្រជាជនខ្មែរនៅតែនិយមប្រើប្រាស់សាច់ប្រាក់ ហើយកាតបង់ប្រាក់មុនមានចំណុចមិនប្រាកដប្រជាត្រង់ថា តើស្ថាប័នហិរញ្ញវត្ថុមួយណាគ្រប់គ្រងប្រាក់របស់ពួកគាត់។

លោក ហ្គ្រេន ណាក់ឃី (Grant Knuckey) ប្រធាននាយកប្រតិបត្តិធនាគារ ANZ Royal បានមានប្រសាសន៍ថា "វាជាកំណើនវិជ្ជមានថ្មីមួយសម្រាប់ផលិតផលដែលកំពុងកើនឡើងនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែនៅតែរង់ចាំមើលថា តើកំណើននេះវិវឌ្ឍទៅល្បឿនកម្រិតណា"។

លោក ណាក់ឃី បានបន្តថា "យើងជឿថា នេះគឺជាទីផ្សារមួយដែលមានសក្តានុពលគួរឱ្យកត់សម្គាល់ ពីព្រោះប្រាក់ចំណូលរបស់ប្រជាជនកំពុងកើនឡើង"។

អ្នកស្រី ឡូរីជន់ បាជី (Lorijon Bacchi) ប្រធានតំណាង និងអ្នកគ្រប់ គ្រងក្រុមហ៊ុន វីហ្សាទទួលបន្ទុកប្រទេសវៀតណាម កម្ពុជា និងប្រទេសឡាវ បានលើកឡើងផងដែរថា អ្នកស្រីមិនអាចនិយាយបានទេថា បច្ចុប្បន្នមានប្រជាជនប៉ុន្មាននាក់មានវីហ្សាកាតទេ។

អ្នកស្រី ឡូរីជន់ បាជី បានមានប្រសាសន៍ ថា "នាងខ្ញុំមិនមានលទ្ធភាពបញ្ចេញតួលេខទាក់ទងទៅនឹងទីផ្សារមួយដែលមានទំហំតូចជាងទំហំជាក់លាក់ណាមួយបានទេ"។ អ្នកគ្រប់គ្រងប្រចាំប្រទេសរូបនេះបានលើកឡើងបន្ថែមទៀតថា អ្នកស្រីគ្រាន់តែអាចនិយាយបានថា មានក្រុមហ៊ុនមកបណ្តាក់ទុនវិនិយោគក្នុងគម្រោងអាជីវកម្មរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា៕ **សុធា**

តមកពីទំព័រទី ១

## ព័ត៌មានស្តីពីកិច្ចប្រជុំគណបក្សប្រជាជន...

បានបោះបង់ការសន្យារបស់ខ្លួនជាមួយប្រជាពលរដ្ឋដែលបានទុកចិត្តមកលើលោកទេ គណបក្សនៅតែទាមទារការឆែកសន្លឹកឆ្នោតឱ្យបានត្រឹមត្រូវដដែល ហើយបើធ្វើមិនបានគណបក្សសង្គ្រោះជាតិនៅតែទាមទារឱ្យមានការបោះឆ្នោតសារជាថ្មីនៅពេលឆាប់ៗឱ្យទាល់តែបាន។ ប្រសិនបើមានការបោះឆ្នោតសារជាថ្មីមែនការបោះឆ្នោតនោះត្រូវតែធ្វើឱ្យបានត្រឹមត្រូវ ហើយមិនអាចពន្យាពេលយូរបានទេ ហេតុនេះហើយបានជាត្រូវកែប្រែប្រព័ន្ធបោះឆ្នោតឱ្យបានត្រឹមត្រូវជាមុនឱ្យបានស្រេចបាច់មិនអាចដល់ពេលបោះឆ្នោតសិមយើងរៀបចំច្បាប់ទម្លាប់នោះទេ”។ រដ្ឋសភានៃប្រទេសអាមេរិកសហភាពអឺរ៉ុបមាន១៨ប្រទេស ប្រទេសអូស្រ្តាលីបានទាមទារឱ្យមានការឆែកឆេរកយុត្តិធម៌ក្នុង ការបោះឆ្នោតនៅកម្ពុជា រីឯជប៉ុនបានបញ្ជូនអ្នកឯកទេសខាងប្រព័ន្ធបោះឆ្នោតសេរីមកធ្វើការសិក្សាមកភ្នំពេញរួចហើយនៅសល់តែសុឆន្ទៈ រួមរបស់គណបក្សសង្គ្រោះជាតិនឹងគណបក្សប្រជាជនប៉ុណ្ណោះ ទើបអាចរំងាប់កំហឹងប្រជាពលរដ្ឋឱ្យស្ងប់បាន។

ខាងក្រោមនេះ ជាសេចក្តីថ្លែងការរួមថ្មីចេញពីជំនួបដំណាងគណបក្សប្រជាជនកម្ពុជានឹងតំណាងគណបក្សសង្គ្រោះជាតិ ថ្ងៃទី១៨កុម្ភៈ ឆ្នាំ២០១៤៕



### សេចក្តីប្រកាសរួមនៃកិច្ចប្រជុំ
### រវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ

*(វិមានព្រឹទ្ធសភា ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤)*

អនុវត្តតាមស្មារតីសេចក្តីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ បានជួបពិភាក្សាគ្នា នៅវិមានព្រឹទ្ធសភា នាថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយបានព្រមព្រៀងគ្នាលើចំណុចសំខាន់ៗដូចខាងក្រោម ៖

១-ស្នើបង្កើតគណៈកម្មការចម្រុះមួយដោយមានសមាសភាពស្មើគ្នា មកពីគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីសិក្សា និងរៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ សំដៅធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

២-ដើម្បីរៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនេះ គណៈកម្មការចម្រុះត្រូវរៀបចំឱ្យមានសិក្ខាសាលាជាតិមួយ ដើម្បីបើកទូលាយឱ្យមានការចូលរួមយោបល់ និងអនុសាសន៍នានាពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ គណបក្សនយោបាយដែលបានចុះបញ្ជី សង្គមស៊ីវិលដែលមានជំនាញលើការងារបោះឆ្នោត ព្រមទាំងតួអង្គពាក់ព័ន្ធ។ ទន្ទឹមនេះ ត្រូវបង្កលក្ខណៈឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់សម្រាប់ការកែទម្រង់ការបោះឆ្នោត ជាអាទិ៍ តាមរយៈវេទិកាសាធារណៈ។

៣-ក្នុងកិច្ចដំណើរការនៃកំណែទម្រង់ការបោះឆ្នោតនេះ ត្រូវបង្កលក្ខណៈឱ្យមានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិនានា។

ក្រុមការងារទាំងពីរនឹងរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំនេះ ជូនថ្នាក់ដឹកនាំគណបក្សរៀងៗខ្លួន ហើយបានឯកភាពបន្តជួបគ្នាលើកក្រោយទៀត ដើម្បីឈានទៅដល់ជំនួបកំពូលរវាងគណបក្សទាំងពីរ។

ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា
ប្រាំ សុខា

ប្រធានក្រុមការងារគណបក្សសង្គ្រោះជាតិ
សុន ឆ័យ

Continued from Page 09

## Winter Olympics kick off ...

their bright uniforms as they slide and sweep with the top curling teams in the world.

As of press time, the United States led the overall medal count with 25 medals (8 gold, 6 silver, 11 bronze). The host country Russia was second with 23 total medals (7 gold, 9 silver, 7 bronze). Largely due to their success in speed skating, the Netherlands was third (6 gold, 7 silver, and 9 bronze).Norway had the most gold medals with 10.

Because of the winter focus of the sports, there are no Cambodian athletes participating in the Sochi games, which primarily consist of athletes from northern countries. Cambodia has however had athletes compete in the Summer Olympics seven times, most recently sending six competitors to the 2012 Summer Games held in London.

The Sochi Winter Olympics will conclude with a closing ceremony on February 23rd. The next Olympic Games will be the 2016 Summer Games in Rio de Janiero, Brazil, while the next Winter games will be held in Pyeongchang, South Korea in 2018. Information from www.olympic.org- was used in this report.



ក្រុមកីឡា (ហុកគី) ស្ត្រី (កាណាដា)




# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)






**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.

**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែវនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient´s x-ray, exam, cleaning at regular price)

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044


តមកទំព័រទី ១៣

## លោក ហ៊ុន សែន សរសើរកិច្ចខិត...

ឱ្យអ្នកតវ៉ាប្រាំនាក់ត្រូវបានបាញ់សម្លាប់ និងជាង៦០នាក់ផ្សេង ទៀតត្រូវបានវាយដំ បាញ់ ឬក៏ចាប់ដាក់ពន្ធនាគារដោយមិនមានការផ្តន្ទាទោស ។

មុនពេលលើកឡើងទាក់ទងនឹងមនុស្ស២៣ នាក់ដែលត្រូវបានចោទប្រកាន់ថា បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអំឡុងសកម្មភាពតវ៉ាកាលពីខែមុន លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ប្រជាជនត្រូវការសេចក្តីសុខ ហើយនឹងភាពសប្បាយរីករាយ ។ ហើយប្រជាជនមិនចូលចិត្តការកកស្ទះចរាចរណ៍ដោយសារអំពើនេះអំពើនោះទេ ។ ដូច្នេះហើយ យើងត្រូវតែការពារសេចក្តីសុខសម្រាប់ប្រទេស និងប្រជាជន ហើយសេចក្តីសុខសម្រាប់ប្រជាជន គឺសំខាន់ខ្លាំងណាស់ ។

លោកបានសួរថា "តើអ្នកដែលបំផ្លាញសេចក្តីសុខរបស់ប្រជាជនគួរតែទទួលខុសត្រូវចំពោះមុខច្បាប់យ៉ាងដូចម្តេច" លោក ហ៊ុន សែន ក៏បានស្នើឱ្យនិស្សិតទាំងនោះពិចារណាអំពីអ្វីដែលពួកគេអាចធ្វើបាន ក្នុងនាមជាអនាគតមន្ត្រីរាជការស៊ីវិល ក្នុងការ ធានាស្ថិរភាព ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍បន្ថែមទៀតថា "ស្ថានភាពនយោបាយមិនអាចមានស្ថិរភាពយូរអង្វែងបានទេ នៅពេលម៉ាក្រូសេដ្ឋកិច្ចមិនអាចធានា ។ តើយើងធ្វើដូចម្តេចដើម្បីជំរុញផលិតកម្មគ្រប់វិស័យ... ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ចឱ្យលើសពី៧ភាគរយ" ។

តំណាងមកពីគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន និងគណបក្សសង្គ្រោះជាតិគ្រោងនឹងជួបពិភាក្សាគ្នានាព្រឹកនេះនៅព្រឹទ្ធសភា ដែលនេះជាជំនួបដំបូងរវាងគណបក្សទាំងពីរតាំងពីមានប្រតិបត្តិការបង្ក្រាបកាលពីខែមុន ដែលនាំឱ្យគណបក្សសង្គ្រោះជាតិលុបចោលកិច្ចចរចាដែលបានគ្រោងធ្វើនៅថ្ងៃទី៣ ខែមករា ។

មន្ត្រីជាន់ខ្ពស់មកពីគណបក្សទាំងពីរបានឱ្យដឹងថា កិច្ចចរចាដែលនឹងផ្តោតសំខាន់ទៅលើលទ្ធភាពកែទម្រង់ប្រព័ន្ធបោះឆ្នោតនេះប្រហែលជាអាចបើកផ្លូវសម្រាប់មេដឹកនាំគណបក្សជួបគ្នាដើម្បីបញ្ចប់ភាពជាប់គាំងផ្នែកនយោបាយ ៕

**សុធា**


# ហាងមាសរស្មី

**SUNSHINE JEWELRY, INC.**

**215-271-2950**



Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong






702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com

# ស្ត្រីដឹកនាំចលនាអហិង្សានៅលីបីរៀ លីម៉ា ក្បូវី



**ដោយ : សុខា**

ខណៈដែលកម្ពុជាកំពុងឈានទៅរកការផ្លាស់ប្តូរក្នុងប្រទេស ក្រោយការបោះឆ្នោតដែលពុំទាន់ចេញលទ្ធផលឱ្យបានដាច់ស្រេចដែលភាគីទាំងពីរពោល គឺគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិមិនទាន់ឈានដល់ការព្រមព្រៀងនោះ គេឃើញមានចលនាអហិង្សានៅកម្ពុជាកំពុងត្រូវទទួលបានការយកចិត្តទុកដាក់។ ក្នុងនោះហេតុផលមួយក្នុងចំណោមហេតុផលសំខាន់ផ្សេងទៀត គឺសម័យកាលផ្លាស់ប្តូរនៅមជ្ឈិមបូពា ឬហៅថាអារ៉ាបស្ព្រីងដែលគេសង្កេតឃើញមានកំលាំងប្រជាជនចូលរួមក្នុងចលនាយ៉ាងច្រើនកុះករ។




ពិនិត្យលើខ្លឹមសារអហឹង្សាចលនានេះត្រូវបានប្រើដែលសាកលលោកចងចាំ គឺចលនាអហិង្សាដឹកនាំដោយមហាត្មហ្គាន់ឌីនៃប្រទេសឥណ្ឌា និងចលនាតស៊ូរបស់អាមេរិកខាងត្បូងទល់នឹងការរើសអើងពណ៌សម្បុរឆ្នាំ៦០ដែលទទួលបានជោគជ័យ។




ជិត១០ឆ្នាំមុន ពោលគឺឆ្នាំ ២០០៣ ព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់មួយបានកើតឡើងនៅប្រទេសលីបីរៀដឹកនាំដោយក្រុមស្ត្រីមានអ្នកស្រីលីម៉ា ក្បូវីជាប្រធានបានតស៊ូ រហូតទទួលជោគជ័យទល់នឹងរបបដឹកនាំរបស់ប្រធានាធិបតីបុរស ថាយឡឺ ផ្តួលរំលំរបបថាយឡឺ ដោយជំនួសមកវិញនូវការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ ជាពិសេស គឺប្រធានាធិបតីដែលចេញពីលទ្ធផលនោះ គឺជាប្រធានាធីបតីស្រីដំបូងក្នុងប្រទេសអាហ្វ្រិកមានឈ្មោះថា អេឡិនចនសុន សឺរីវ។







គួរបញ្ជាក់ផងដែរ អ្នកសីលីម៉ាក្បុវី ដែលជាសកម្មជនក្នុងចលនាអហឹង្សានៃប្រទេសលីបីរៀបាននិពន្ធសៀវភៅដែលមានចំណងជើងថា Mighty Be Our Power លោកស្រីក៏ជាចំណែក ដ៏សំខាន់នៅក្នុងភាពយន្តឯកសារ Pray Devil Back to the Hell ហើយលោកស្រីជាពានរង្វាន់សន្តិភាពពិភពលោកផងដែរ ៕

The City of Lowell is seekingqualified candidates for the position of City Manager as the Chief Administrative Officer of the City, directly responsible to the City Council, under a plan E government.

The successful candidate should have a strong managerial and municipal background with excellent written, oral skills and fiscal abilities. The position requires a Bachelor's degree in Public Administration, Business Administration, or a related field and at least 5-7 years of executive management experience. A Master's Degree is highly preferred and /or comparable government industry experience. Municipal management experience preferred.

**Salary: Negotiable**

A full description is available on the City of Lowell's Website: http://www.lowellma.gov/humanrelations/Pages/General/CityJobs.aspx Applicants should send a resume, cover letter, and 3 references to City Council c/o Mary Callery, Human Relations Director, City of Lowell Human Relations Office, Room 19, 375 Merrimack St, Lowell, Mass. 01852 by 4:00PM February 28,2014.The City is an EOE/AA/504 Employer.

Celebrate Cambodian Arts

Thursday, April 3, 2014, 1 p.m.-7p.m.

*featuring*

Angkor Dance Troupe
UMass Lowell's World Music Ensemble
Poetry by Thararith Kho
Pannel Discussion with Scholars:
*'Posttraumatic Stress in Refugee Cultures'*

**Dance Performance: 7 p.m.**
Tickets: $25 for the public
UMass Lowell students free (limit 200 seats)

In collaboration with the Music Dept., Center for Arts and Ideas, Center for Asian-American Studies and others, Cambodian artists will present dance, poetry, sculpture, and more.

For tickets and schedule details, visit www.angkordance.org.

UMASS University of Massachusetts Lowell
Learning with Purpose
ARTS AND IDEAS

តមកទំព័រទី ១០

# សហជីព: កម្មករយ៉ាងតិច២០ម៉ឺននាក់...

**៥.**តំណាងក្រុមហ៊ុនទាំងអស់ត្រូវដកបណ្តឹងដែលប្រឆាំងសហជីព និងកម្មករ និយោជិត

**៦.**សុំឱ្យទទួលយកកម្មករដែលត្រូវបញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ ព្រមទាំងផ្តល់ប្រាក់រំលឹក និងអត្ថប្រយោជន៍ផ្សេងៗ និងចំនុចទី៧ ត្រូវទូទាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់ជូនដល់កម្មករដែលនិយោជកបានកាត់ក្នុងអំឡុងពេលធ្វើកូដកម្ម។

ប្រធានសហភាពសហជីពកម្ពុជា លោក រ៉ុង ឈុន មានប្រសាសន៍ថា បាតុកម្មដែលសហជីពគ្រោងនឹងធ្វើនៅពេលខាងមុខនេះនឹងមានកម្មករ-កម្មការិនីយ៉ាងតិច២០ម៉ឺននាក់ចូលរួម ព្រោះពួកគាត់ កម្មករ កម្មការិនី នឹងចូលរួមច្រើនហើយ ព្រោះជាប្រយោជន៍ផ្ទាល់មិនមែនប្រយោជន៍របស់អ្នកណាទេ អញ្ចឹងសូមឱ្យកម្មករកម្មការិនីទាំងអស់ហ្នឹងកុំមើលបំណាំគ្នាត្រូវតែចូលរួមសហការគ្នាទាំងអស់គ្នាឱ្យបានសស្រាកសស្រាំនេះហើយ ដែលយើងទទួលបានដំណោះស្រាយ ហើយប្រសិនយើងធ្វើហើយមើលបំណាំគ្នានោះវាមិនបានជោគជ័យទេ។

លោក រ៉ុង ឈុន បន្តថា ប្រសិនបើមានអាជ្ញាធរណាមួយចេញមុខមករារាំងការចែកខិត្តប័ណ្ណនោះ ក៏សហជីពមិនរាថយ ព្រោះរឿងនេះ មិនទាក់ទងនឹងរឿងនយោបាយនោះទេ។









កិច្ចការទាំងនេះ គឺផ្តល់ផលប្រយោជន៍ទៅដល់ពួកគេច្រើន ជាពិសេសទាមទារឱ្យដំឡើងប្រាក់ឈ្នួលគោលដល់១៦០ដុល្លារ ដើម្បីទ្រទ្រង់ជីវភាពរស់នៅបានល្អជាងមុនឪខ្ញុំគិតថា ជាផលប្រយោជន៍

ប្រធានសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយណភ័ណ្ឌកាត់ដេរកម្ពុជាលោកស្រី ម៉ម ញឹម មានប្រសាសន៍ថា ស្របពេលដែលរដ្ឋាភិបាលកម្ពុជានៅតែមិនព្រមដំឡើងប្រាក់ឈ្នួលកម្មករដល់១៦០ដុល្លារ ពួកគេបាននិយាយដូចៗគ្នា គឺមិនពេញចិត្តនឹងប្រាក់ឈ្នួលប៉ុណ្ណឹងនោះទេ មិនតែប៉ុណ្ណោះរដ្ឋាភិបាលបានបំបិទសិទ្ធិបញ្ចេញមតិប្រជាពលរដ្ឋ។ អ្នកស្រីបន្តថា នៅពេលដែលអ្នកស្រីទៅជួបជាមួយកម្មករពួកគេតែងតែទទូចឱ្យសហជីពដឹកនាំធ្វើកូដកម្មទ្រង់ទ្រាយធំ ។

ប្រធានសហភាពការងារកម្ពុជាលោក អាត់ ធន់ មានប្រសាសន៍ថា ប្រសិនបើការធ្វើកូដកម្មនេះនៅតែមិនទាន់មានដំណោះស្រាយសហព័ន្ធសហជីពសមាគម និងកម្មករនិយោជិតគ្រប់វិស័យព្រមានធ្វើកូដកម្មទ្រង់ទ្រាយធំនៅទូទាំងប្រទេសចាប់ពីថ្ងៃទី១២ដល់ថ្ងៃទី១៥ ខែមីនា ដោយកម្មករនិយោជិត និងមន្ត្រីរាជការនឹងធ្វើកូដកម្មមិនទៅធ្វើការ។ ហើយនៅថ្ងៃទី១៦ដល់ថ្ងៃទី១៩ ខែមីនា កម្មករនិយោជិតនឹងទៅកន្លែងធ្វើការតែមិនបំពេញការងារ ៕


## កម្មវិធីថែសុខភាពតាមគេហដ្ឋានសម្រាប់ចាស់ៗ និងជនពិការភាព

- នាងថែខ្ញុំដូចជាម្តាយបង្កើត ខ្ញុំសប្បាយចិត្តណាស់
- នាងស្រឡាញ់និងថែខ្ញុំដូចជីដូនបង្កើត
- នាងចំអិនម្ហូប បោសសំអាតផ្ទះ បោកខោអាវ ហើយស្តាប់រឿងខ្ញុំពេលខ្ញុំកើតទុក្ខ
- ខ្ញុំមានពេទ្យមកពិនិត្យសុខភាពជាប្រចាំ
- នាងរលឹកពេលដែលខ្ញុំត្រូវញ៉ាំថ្នាំ គ្រប់ពេលវេលា
- នាងជូនខ្ញុំដើរលេងលំហែកាយ
- នាងជួយខ្ញុំទិញម្ហូបនិងសំភារៈប្រើប្រាស់
- កូនខ្ញុំមិនព្រួយអំពីភាពអត់ការងារធ្វើ ហើយបាននៅក្បែរខ្ញុំគ្រប់ពេលវេលា
- ព្រឹទ្ធាចារ្យជាដុំពេជ្យក្នុងសង្គមយើង ចូរអ្នកទាំងអស់ខំថែទាំគាត់អោយមានអាយុវែងនិងសុខភាពល្អ។

ក្រុមហ៊ុនយើងខ្ញុំកំពុងជ្រើសរើសបុគ្គលិកធ្វើការ
សម្រាប់ពត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទង

ម៉ូនីដា (២៦៧) ២៦២-៣៩២៩ ដេវីដ (២៦៧) ៩១៨-៨៤៩៣

HOME CARE Aurora




តមកពីទំព័រទី ៣

# នាយកប្រតិបត្តិទូរទស្សន៍អិលធីស៊ីក្នុង...

ព្រមទាំងគណប្រតិភូអាមេរិកច្រើនរូបទៀត រួមមាននាយិការមន្ទីរពេទ្យសហគមន៍ឡូវែលអ្នកស្រី ដរកាស ហ្គ្រិក សាអ៊ីតុ (Dorcas Grigg-Saito, Executive Director of Lowell Community Health Center), អ្នកស្រី ខាស៊ី រ៉េតធីខឺ ( Kathy Reticker, Executive Director of Acre Family Child Care) ព្រមទាំងសិក្ខាកាមមកពីខាងម៉ែរីម៉ាក វ៉ាលីសេនបក្ស(Merrimack Valley Sandbox) ។

ដំណើរខាងលើនេះប្រព្រឹត្តទៅអស់រយៈពេលពីរសប្តាហ៍ចាប់ពីថ្ងៃទី១៦ ខែមករា ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ។

ក្រោមការរៀបចំរបស់ម៉ែរីម៉ាក់វ៉ាលីសេនបក្ស ។ ដំណើរទស្សនកិច្ចនេះ មិនមែនទើបចាប់ផ្តើមឆ្នាំនេះទេ គឺបានធ្វើឡើងបីបួនដងរួចមកហើយ ហើយបានផ្តល់ឱកាសដល់បញ្ញវ័ន្ត និងសហគ្រិនអញ្ជើញពីសហគមន៍នៃសហរដ្ឋអាមេរិក បានទៅចែករំលែកដោះដូរបទពិសោធន៍ និងចំណេះដឹងល្អៗដល់សហគមន៍នៃប្រទេសឥណ្ឌា។

សន្និសីទដែលពួកគេបានចូលរួមនោះមានឈ្មោះថា កិច្ចពិភាក្សាវឌ្ឍនភាព។ ក្រៅពីនេះមានការចុះទៅដល់ទីសំខាន់ៗនានាមានប្រាសាទ វិហារ ស្ទឹង ផ្សារ ស្វែងយល់ពីជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកស្រុកឥណ្ឌា។

អ្នកស្រី ចេស៊ីការ បានសម្តែងការចាប់អារម្មណ៍ថា អ្នកស្រីទទួលបានផ្លែផ្កា និងចំណេះដឹងជាច្រើនពីដំណើរទស្សនកិច្ចនេះ ដោយមើលឃើញពីសកម្មភាពនៃអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្មជួយដល់ប្រជាជន និងសហគម ដូចជាមានអង្គការមួយដែលធ្វើអាហារថ្ងៃត្រង់ផ្តល់ជូនដល់ក្មេងលើសពីមួយលាននាក់ឱ្យបានហូបបាយ និងជាហេតុផលក្រសោបក្មេងទាំងនោះឱ្យបានចូលរៀន។

នៅមានចំណុចជាច្រើនដែលអ្នកស្រីភ្ញាក់ផ្អើលមិនធ្លាប់ឃើញនៅឡើយ គឺស្ថានភាពចរាចរណ៍ដែលពុំមាននរណាគោរពច្បាប់ចរាចរណ៍ ប៉ុន្តែងាកទៅមើលអត្តចរិតរបស់ប្រជាជន គឺចរិតល្អរួសរាយរាក់ទាក់អ្នកស្រីលើកឡើងមានកុមារមួយក្រុមសុំស្គាល់នាង ព្រោះពួកគេចង់ថតរូបជាមួយអ្នកស្រី ៕


ប្រជាជនឥណ្ឌាងូតទឹកនៅទន្លេគែងស៍ (Genges River) ក្នុង Varanasi ប្រទេសឥណ្ឌា


រូបភាពនៅហ្គូអា (Goa)


វិហារសាសនាគ្រីស្តនៅហ្គូអា (Goa)


បុរសសម្រូតចុះពីលើដើមដូង


អ្នកស្រី ខាស៊ី រ៉េធីខឺ និង ចេស៊ីកា នៅ វ៉ារ៉ាន់ណាស៊ី (in Varanasi)


ផ្សារបៃតង (Green Market in Goa)


វាំង ប៊ីសស្សប់ (Bishop's Palace in Goa)


បុរសកំពុងដាំបាយ សម្រាប់កុមារលើស ១លាននាក់ នៅ Akshya Patra


ស្ត្រីឥណ្ឌាដែលនៅវិហារចំណាស់ជាងគេនៅ Hampi


រូបភាពសាសនាលក់នៅព្រះវិហារ វីរូផាក់ស្សា(at Virupaksha Temple)

Continued from page 13

## Hun Sen Lauds Own Efforts

"The people need peace and the people need happiness. They do not need traffic jams from other actions, so we have protected peace for the country and the people. Peace for the people is necessary," he said, before making an apparent reference to the 23 people charged with property destruction in last month's protests.

"How should the people who destroy the people's peace take responsibility before the law? " he asked

Mr. Hun Sen also asked the students to consider what they could do as future civil servants to help ensure stability.

"Political stability cannot be maintained for a long time while the macroeconomy is not guaranteed, " he said. "What can we do to push production in all sectors…to push the economy to grow above 7 percent?"

Representatives from Mr. Hun Sen's ruling CPP and the CNRP are set to meet this morning at the Senate for the first meeting between the parties since last month's suppression led to the CNRP abandoning talks that had been planned for January 3.

Senior officials from both parties say the talks, which will focus on the possibility of electoral reform, could pave the way for party leaders to meet to end the political deadlock.

តមកពីទំព័រទី ១២

## គម្រោងសាកល្បងផ្តល់...

សហប្រតិបត្តិការអន្តរជាតិជប៉ុន ហៅកាត់ថា JICA នេះឈានដល់ទីបញ្ចប់ ។

លោក ឌីម៉ង់ បានលើកឡើងថា ក្រុមហ៊ុនចំនួនប្រាំបួនកំពុងតែរត់ការ ធ្វើកិច្ចសន្យាដើម្បីប្រតិបត្តិប្រព័ន្ធថ្មីនេះ ក៏ប៉ុន្តែលោកមិនអាចចាំឈ្មោះក្រុមហ៊ុនទាំងនោះទេ ។

លោក អេហ្គាមិ ម៉ាសាហ៊ីកុ (Egami Masahiko) អ្នកនាំពាក្យអង្គការ JICA បានលើកឡើងថា បើទោះជាលោកជានិច្ចកាលតែងតែរំពឹងថា គម្រោងសាកល្បងសេវារថយន្តក្រុងនឹងទទួលបានជោគជ័យក៏ដោយ ក៏ការផ្សព្វផ្សាយអំពីរថយន្តក្រុងក្នុងចំណោមនិស្សិតដែលភាគច្រើនជិះរថយន្តក្រុងទៅសាលា ឬសាកលវិទ្យាល័យបានជួយជំរុញគម្រោងនេះលើសពីការរំពឹងទុករបស់លោកដែរ ។

លោកបានមានប្រសាសន៍ថា "យុវជនចែករំលែកព័ត៌មានកាន់តែងាយស្រួលនៅតាមប្រព័ន្ធព័ត៌មានសង្គមក្នុងអ៊ិនធើណិតនេះតែងតែជាផែនការរបស់យើងក្នុងការជំរុញទឹកចិត្តសិស្សនិស្សិតឱ្យប្រើប្រាស់សេវាកម្មនេះ" ។

ការនិយមប្រើសេវារថយន្តក្រុងកាន់តែកើនឡើងៗមិនមែនជាព័ត៌មានល្អទាំងអស់នោះទេ ព្រោះវាមានន័យថា សាលារាជធានី និងក្រុមហ៊ុនដែលទទួលបានកិច្ចសន្យាអាចបង្កើនកម្រិតសេវារបស់ខ្លួនផ្ទាល់ ។

លោក ម៉ាសាហ៊ីកុ បានមានប្រសាសន៍ថា "ប្រព័ន្ធដ៏តូចមួយអាចមានភាពងាយស្រួលក្នុងការអនុវត្ត ប៉ុន្តែចាំបាច់ត្រូវតែពិចារណាដោយប្រុងប្រយ័ត្ន ពីព្រោះបើមានអ្នកធ្វើដំណើរច្រើន សេវាកម្មនេះនឹងមិនឆ្លើយតបទៅនឹងតម្រូវការសាធារណជនទេ" ៕

**ប៊ុននី**

Continued from page 12

## Wing, Foreign Trade Bank

"It didn't take off. Not because it wasn't a good product, but because no one was aware it was there," he said. "It would take millions of dollars to build Wing's distribution network. This gets the cards in many more hands."

Mr. Felsing said FTB had 42 points of sale for its prepaid Visa card, but now with Wing, it is more than 1,000.

Mr. Perkins said Wing plans to expand the points of sale to 2,000 within the next two months.

Banking executives on Monday said it remains to be seen whether Cambodians will opt for a prepaid Visa card, as most of the population still prefers cash and prepaid cards offer an uncertainty about which financial institution controls the money on them.

"It's a positive addition to the growing products in the country, but it remains to be seen how quickly it will be taken up," ANZ Royal CEO Grant Knuckey said.

"We certainly believe that this is a market that has considerable potential as the wealth of the population grows," he said.

Lorijon Bacchi, Visa's chief representative and country manager for Vietnam, Cambodia and Laos, said she could not say how many Cambodians currently hold Visa cards.

"I'm unable to release figures on a market less than a certain size," she said, adding only that the company is "invested" in Cambodia.


ANGKOR AUTO SERVICE,INC.
ហាងជួសជុលរថយន្ត "អង្គរ"
Free Estimate
Auto Body and Maintenance
BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting



មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនសួរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425





ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ
Rathe´s Auto Service

State and Emission
Inspaction General
Repairs and Maintenance




MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY

- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ដំណើរទៅ"ឡុងប៊ិច"ក្រុងដែលមានខ្មែររស់នៅច្រើនជាងគេនៅស.រ.អា.

**ពិន សំខុន សម្រាប់ខ្មែរផុស ស.រ.អា.**

នៅលេខមុនៗយើងបានសរសេរពីការធ្វើដំណើរទៅកាន់តំបន់ផ្សេងៗកំដរអារម្មណ៍នឹងទស្សនៈលោកអ្នកអានឱ្យអណ្តែតអណ្តូងជាមួយយើងខ្ញុំ គ្រាន់កែអផ្សុក ឬក៏អាចជាព័តិមានសម្រាប់លោកអ្នករៀបចំខ្លួនធ្វើដំណើរដ៏អស្ចារ្យប្រចាំជីវិតមួយផង ក៏មិនដឹង ។ តែថ្ងៃនេះយើងសូមជូនដំណើរទៅកន្លែងផ្សេងមួយថ្មីទៀត ដែលជាក្រុងសម្បូរខ្មែររស់នៅច្រើនជាងគេនៅសហរដ្ឋអាមេរិកនេះ គឺក្រុង"ឡុងប៊ិច"នៃរដ្ឋ "កាលីហ្វ័រញ៉ា" ។ ពីក្រុង"ឡូវែល"ដែលគ្រាន់តែជាទីក្រុងទី២ទៅគេត្រូវឡើងយន្តហោះនៅ "បូស្តុន"ហោះម៉ោង៧:៤៥ព្រឹកអ្នកដំណើរត្រូវទៅដល់ព្រលានយន្តហោះឱ្យបាន២ម៉ោងមុន បើមិនបានទេនោះ ត្រូវទទួលការផាកពិន័យជាប្រាក់ ឬជាពេលវេលាត្រូវរង់ចាំជើងយន្តហោះថ្មីយ៉ាងយូរ ។រីឯយើងដែលនៅ "ឡូវែល"ត្រូវក្រោកពីម៉ោង៣ព្រហ៊ាមហើយចេញពីផ្ទះនៅម៉ោង៤ ទើបទាន់ជើងយន្តហោះ ហើយយើងបំពេញភារៈកិច្ចនេះយ៉ាងនឿយហត់ដោយសារ **១-**ឥឡូវនេះគេត្រូវបង់ថ្លៃវ៉ាលីសមួយ$២៥ **២-**អាកាសធាតុដ៏សែនត្រជាក់ នាព្រលឹមថ្ងៃទី១១ កុម្ភៈនោះធ្លាក់ដល់១៦អង្សារ


ជួបជុំគ្រួសារនៅព្រលានយន្តហោះកាលីហ្វញ៉ា ឡាក់


អាគារខ្មែរនៅលើផ្លូវអាណាហែម


ទិដ្ឋភាពខាងក្នុងអាគារខ្មែរ



ប្រធាន (ពាក់អាវស) និងអនុប្រធានក្រុងខ្មែរ បង្ហាញពីផ្លូវអាណាហែម



ពាណិជ្ជកម្មខ្មែរនៅផ្លូវអាណាហែម

៧ម៉ោងឆ្ពោះទៅអាកាសយាន"ឡាក់កាលីហ្វ័រញ៉ា" ឆ្ងាយដូចគេជិះយន្តហោះទៅក្រុង"ប៉ារីស"ដែរ ។ ឆ្លៀតឱកាសទៅការសាច់ញាតិផង សុបិន ខ្ញុំ និង ប៉ុណ្ណារ៉ូ ក៏យកពេល១សប្តាហ៍សម្រាប់កំសាន្ត និងសរសេរជូនជាចំណងដៃដល់មិត្តអ្នកអានក្នុងឱកាស "វ៉ាឡង់តាញដេយ៍"ផង ។

យន្តហោះនឹងចេញដំណើរពី"បូស្តុន"នៅ **៣-**យើងមានកូនក្មេងអាយុ៤ឆ្នាំទៅជាមួយដំណើរយើងផង ។ ម៉ោង៧:៥០នាទី យើងបានចូលយន្តហោះតែបានកន្លែងអង្គុយឆ្ងាយពីគ្នាធ្វើឱ្យយើងអន់ចិត្តរួចម្តងហើយ ទំរាំរកកន្លែងបាន២ឱ្យម្តាយនឹងកូនតូចអាចអង្គុយជាប់គ្នាបាន ប៉ុណ្ណារ៉ូ មិនដឹងហេតុដូចម្តេចផ្តើមយំរក"ជីដូនអរានដីមា" នៅពេលនោះ ទោះជាមិនដែលធ្លាប់មានជីដូននៅជិតខ្លួនក៏ដោយ ។ នៅពេលចាប់ផ្តើមហោះហើរ ទើបយើងដឹងថា "យន្តហោះអាមេរិកាំងអែរលាញ"គ្មានផ្តល់ចំណីអាហារបរិភោគដល់ភ្ញៀវទេ បើឃ្លាន ឬស្រេកក្នុងយន្តហោះត្រូវបញ្ជាទិញទើបមានអ្វីបរិភោគ នេះជាការខកចិត្តម្តងទៀត


ប៉ុណ្ណារ៉ូ បានជួបជីដូនជាលើកដំបូង





ប៉ុណ្ណារ៉ូ ឃ្លានយំហៅរក "ក្រង់ម៉ា"ម្តងទៀត មិនដឹងហេតុអ្វី? ដំណើរតាមជើងយន្តហោះ នាប៉ុន្មាន១០-១៥ឆ្នាំចុងក្រោយមិនមានលក្ខណៈអធឹកអធមដូចគ្នានឹងអតីតកាលទេ ដោយសារទស្សនៈថ្មីនៃដំណើរតាមយន្តហោះពាណិជ្ជកម្មសម័យគឺមិនខុសពីដំណើរតាមរថយន្តក្រុងរបស់សាធារណ

**តទៅទំព័រទី ២១**

តមកពីទំព័រទី ២០

# ដំណើរទៅ"ឡុងប៊ិច"ក្រុងដែលមានខ្មែរ...

ជននោះទេ ដូច្នេះហើយការខកចិត្តរបស់យើងជាអ្នកដំណើរក៏ត្រូវយល់ពីការលំបាកគ្រប់គ្រងនាឱកាសលំបាកសេដ្ឋកិច្ចប្រទេសតម្រូវឱ្យរក្សាតម្លៃបានថោកជូនភ្ញៀវ ។ តែយ៉ាងណាក៏ដោយយើងអាចទ្រាំអង្គុយយ៉ាងចង្អៀតជាង៦ម៉ោងបានដោយសារភាពរីករាយនឹងជួបក្រុមគ្រួសារ ជាពិសេសនឹងបានដោះអាវធូន់ក្រាស់ចេញ ព្រោះកំដៅឡើងដល់៧០អង្សារង់ចាំនៅពេលទៅដល់"កាលីហ្វញ៉ា" ។

"ឡាក់កាលីហ្វ័ញ៉ា"ព្រលានយន្តហោះឆ្នេរខាងលិចម៉ោង១០:៤០យើងបានមកដល់ដោយសុវត្ថិភាព ក្រុមបងប្អូននឹងមិត្តភ័ក្រ្តមកទទួលរីករាយដោយបានជួបគ្នាបន្ទាប់ពីបែកគ្នាយ៉ាងយូរ ។ យើងនាំគ្នាឡើងរថយន្តសំដៅទៅក្រុង "ឡុងប៊ិច"នៅចម្ងាយ១ម៉ោងទៅខាងត្បូងឈៀងខាងលិច។ នៅទីនោះយើងបានជួបជុំក្រុមគ្រួសារមានបង ប្អូន កូន ចៅ ក្មួយ មា មីង និងមិត្តភ័ក្រ្តជាច្រើន ប៉ុណ្ណារ៉ូ ក៏បានជួប"ជីដូន"ដូចក្តីប្រាថ្នាមែនធ្វើឱ្យគេរីករាយជាទីបំផុត។



នៅ"ឡុងប៊ិច"មានខ្មែរចំនួន៩,៥ម៉ឺននាក់មកតាំងទីរស់នៅតាំងពីប្រមាណ៣០ឆ្នាំមកហើយ នេះគ្រាន់តែជាចំនួនផ្លូវការណ៏តែប៉ុណ្ណោះ ឯក្រៅផ្លូវការណ៏មានប្រមាណ៨ម៉ឺនឯណោះជាតំបន់ដែលគេមើលឃើញថា មានខ្មែរជាជនភាគតិចរស់នៅច្រើនជាងគេនៃសហរដ្ឋអាមេរិកនេះ។ ប្រជាពលរដ្ឋគ្រប់សាសន៏នៅ "ឡុងប៊ិច"មានចំនួនប្រមាណ៥០ម៉ឺននាក់ តែមានលទ្ធភាពរួមរស់ផ្តុំគ្នាបានបង្កើតជាតំបន់នៃសហគមន៏ផ្ទាល់ខ្លួន ដូចជា"លីតធិលសាយគួន Little Saigon" របស់ជនជាតិវៀតណាម នៅ"សានតាអាណា្យានតា Ana" ដូចជាមាន "ឥណ្ឌាថោនីន dia Town"នៅផ្លូវ"ផៃយូនា" ឬមាន "ខាំបូឌាថោន Cambodia town"នៅផ្លូវ"អាណាហែមAnaheim" ជាដើម...។ល។ ធ្វើឱ្យ"ឡុងប៊ិច"មិនត្រឹមតែសួនច្បារចម្រុះពណ៌ប៉ុណ្ណោះទេ នៅមានមនុស្សចម្រុះសាសន៏រួមរស់នៅ និងមាននាំវប្បធម៌ពីប្រទេសនីមួយៗមកលាយចម្រុះគ្នាថែមទៀត ។ នេះជារូបភាពចម្រុះរស់ជាតិ គួរឱ្យគយគន់របស់ "ឡុងប៊ិច"បន្ថែមដោយឆ្នេរខ្សាច់សមុទ្រនៅ"ឡាគូណាឡាងុនា"ដ៏ស្រស់អស្ចារ្យនៅមានតំបន់ចម្រុះពណ៌ឆ្ងាយពីនេះបន្តិច ដែលគួរចាប់អារម្មណ៏ទៅមើលកំសាន្តដែរនោះ ដូចជា "ថៃថោន Thai Town"របស់ជនជាតិថៃដែលនៅចុងផ្លូវ "ហូលីវូត Holliwood"នៅមានតំបន់"ហូលីវូត"ដែលជាតំបន់សិល្បៈភាពយន្តដ៏ធំល្បីងល្បើយនៅជាប់នឹង "បេវើលីហៀល Beverly Hills" ឬ"សាន់តាម្ងនីកា្យានតា Monica.ដ៏ល្បីល្បារស់នៅដោយមានតួឯកកុនល្បីឈ្មោះជាច្រើននៅពាសពេញដែលចង់ឱ្យមានឱកាសនឹងឃើញចង់ជួបដោយផ្ទាល់អ្នកទាំងនោះ ដូចជាចង់ឃើញ"សត្វចំឡែក"អ៊ីចឹងដែរ ។


ទិដ្ឋភាពឆ្នេរសមុទ្រនៅឡុងប៊ិច


ទិដ្ឋភាពឆ្នេរសមុទ្រនៅឡុងប៊ិច

"ឡុងប៊ិច"ជាផ្នែកមួយនៃរដ្ឋ"កាលីហ្វ័រញ៉ា" ដ៏ធំទូលាយដោយទំហុំធាតុអាកាសក្តៅ គួរឱ្យចង់រស់នៅបើប្រៀបធៀបទៅនឹង"ឡូវែល" ដ៏តូចល្អិត និងត្រជាក់ក្រោមសូន្យជាច្រើនខែក្នុងមួយឆ្នាំនោះ ប៉ុន្តែបើប្រៀបធៀបជាភាគរយជនជាតិខ្មែរក្នុងតំបន់ "ឡូវែល"មានខ្មែររហូតដល់ជិត៣០ភាគរយលើស"ឡុងប៊ិច"ដែលមានតែប្រមាណ២ភាគរយតែប៉ុណ្ណោះ ។ ក្រុងទាំង២មាន"ទីស្តីការអគ្គកុនស៊ុល"ដូចគ្នាមានតំបន់ដែលត្រូវបានទទួលស្គាល់ថាជា"ក្រុងខ្មែរ"ដូចគ្នាប៉ុន្តែខាង"ម៉ាសាឈូសេត"មានតំណាងជាខ្មែរជាប់ឆ្នោតក្នុងក្រុមប្រឹក្សាក្រុងនៅក្រុង"លីន"រដ្ឋ "មាសាឈូសែត"ដដែលកាលពីឆ្នាំមុននៅ "ឡូវែល"មានជាប់ខ្មែរម្នាក់ទៀតដែរ តែនៅ "ឡុងប៊ិច"គ្មានដំណាងជាប់ឆ្នោតទេ ។

**(នៅមានត )**



# CLASSIFIED ADS




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត
តម្លៃ $10




របាំបុរាណខ្មែរ ដោយសាគូ សាមុត
តម្លៃ $10




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត
តម្លៃ $10




ក្រុងភ្នំពេញមុនឆ្នាំ១៩៥៤
តម្លៃ $10




CAMBODGE
តម្លៃ $5




អង្គការជានរណា?
បភាគ តម្លៃ $5/1

| Name | Phone # |
|---|---|
| Shipping Address | Email |
| City, State, Zip | Book Title(s) |

## BOOK ORDER FORM

Checks or Money Order Payable to KhmerPost USA, LLC
អាចទិញនៅអាស័យដ្ឋាន៖ 45 Merrimack St., Suite 218A, Lowell, MA 01852


**Your Bussiness**
Card is Here for $50/mon
ពាណិជ្ជកម្មរបស់អ្នកនៅទីនេះចំណាយ
ត្រឹមតែ $50 ក្នុង១ខែ







Golden Video Shop
Providence
មានលក់ថាសចម្រៀង
និងខ្សែវីដេអូ-ខ្មែរ-ចិន-ថៃ
(401)-808-9336
VM LAPTOPS CENTER
- VANNAK MOEUN (Manager)
មានជួសជុល-ទិញ និង លក់ " ឡាបថប " គ្រប់យ៉ាង
301 Reservoie Ave.
Providence, RI 02907

លក់ហាងធ្វើក្រចក និង ស្ប៉ា បន្ទាន់
បើកដំណើរការរយៈពេល៧ឆ្នាំ
ទទួលបានចំនូលខ្ពស់
មានទីតាំងល្អធំទូលាយនៅ Derry,NH
ពត៌មានបន្ថែមសូមទំនាក់ទំនងតាម-
ទូរស័ព្ទលេខ 781 704 3418

Nail & Spa Salon for Sale
. 7 Nail Stations
. 4 Pedicure Chairs,plus 3 rooms
. For Facial,Massage and waxing
We also need Nail Tech
Contact:Ms. KIM 781 704 3418

ប្រូវីដិនខ្មែរវីដេអូ
មានជួសជុល និងលក់កុន
ចិន-ថៃ-ខ្មែរ-ឥណ្ឌា
គ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ
ខារ៉ាអូខេថ្មីៗ
742 Potters Avenue
Providence, RI 02907
ទូរស័ព្ទ : (401) 787 6663

Chheng & Associates
- Professional Income Tax Preparation Service
ធ្វើពន្ធដារប្រចាំឆ្នាំ
Immigration Document Preparation
បំពេញឯកសារអន្តោប្រវេសន៍
@ Bamboo Garden Restaurant
*Serving:* the best Papaya Salad, Noodle Soup, & Me-Kantaing,
376 Elmwood Ave. Providence RI
(401) 996-0225, (401) 432-7002,
teechheng@hotmail.com


**HELP WANTED ជ្រើសរើសបុគ្គលិក**

A busy Restaurant in Philadelphia
Seeking for a Chef to cook full time
Competitive salary.
ត្រូវការចុងភៅ ធ្វើការពេញម៉ោងប្រាក់ខែល្អ
ធ្វើការក្នុងភោជនីយដ្ឋាន សំបូរភ្ញៀវចេញចូល នៅហ្វីឡាដែលហ្វៀ
Please call Jimmy for details.
សូមហៅ ជីមមី **215-688-1313**

## Freeland Interpreter Opportunity

Lionbridge holds a contract with the Social Security Administration to provide interpreters for Disability Adjudication and Review. We are recruiting for freelance Khmer/Cambodianon-site interpreters for the Boston area.

Requirements: U.S. citizen or green card holder with some interpretation experience (preferred).

Starting rate $30/hr! Higher rates available for those with interpretation experience.If you are interested contact

wasinterpresumes@lionbridge.com

# វិរៈបុរសដែលគួរចងចាំ



ដោយ : ខ្មែរផុស
ដកស្រង់ពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជា និង វីរជនខ្មែរ
អ្នកនិពន្ធ សាគូ សាម៉ុត
គ្រឹះស្ថានបោះពុម្ពផ្សាយ-បណ្ណាគារ
អង្គរ ភ្នំពេញ ទូរស័ព្ទលេខ ០១២ ៤៥៥ ៨៨៥

តពីលេខមុន

## ក. សំណង់ សាសនា

សំណង់ជាច្រើន ក្នុងទិសដៅសាសនា បានត្រូវសង់នៅគ្រប់តំបន់ នៅក្នុងព្រះអធិរាជាណាចក្រ តាំងពីមាត់ស្ទឹងមេណាម រហូតដល់មាត់ស្ទឹងមេគង្គ និង នៅក្នុងប្រទេសលាវខាងត្បូង ។ សំណង់ដែលគួរកត់សំគាល់ គឺ ប្រាសាទបន្ទាយឆ្មារ ។ សំណង់ធំៗឯទៀត ត្រូវបានសង់នៅជុំវិញព្រះរាជធានី ។

### ◆ ប្រាសាទ បន្ទាយស្រី និង តាព្រហ្ម (១១៨៦)

ដោយហេតុគ្មានសីលាចារឹក គេមិនអាចសន្និដ្ឋានបាន នូវបូជនីយទិស នៃ ប្រាសាទនេះឡើយ ។ នៅខាងមុខប្រាសាទជរានេះ មានស្រះមួយធំឈ្មោះ ស្រះស្រង់ ដែលមានកំពង់ដីល្អ មានរូបនាគជារបង ។

ប្រាសាទតាព្រហ្ម គឺត្រូវបានស្ថាបនាឡើង ដើម្បីបូជាថ្វាយព្រះមាតារបស់ព្រះអង្គ ដែលមានរូបចម្លាក់ជាតំណាង ព្រះប្រាជនបរមីតា (សីលធម៌គ្មានខ្ចោះនឹងព្រះមាតា នៃ គ្រប់ព្រះពុទ្ធ) ព្រមទាំង ថ្វាយព្រះគ្រូផង ។ គឺជាព្រះរាជវិហារ ដែលមានសាសនជន ជាង ១២.០០០ នាក់ រស់នៅ ដោយរាប់បញ្ចូល ១៨ នាក់ ផង និង អ្នកឲ្យធម៌ ជាង ២.០០០ នាក់ផង ។ ព្រះរាជវិហារនេះ ត្រូវបានភូមិ ជាង ៣.០០០ នៅជុំវិញ ផ្តល់នូវ សម្ភារៈ និង គ្រឿងឧបភោគបរិភោគ ។

### ◆ ប្រាសាទព្រះខ័ន (១១៩១)

ប្រាសាទនេះ ប្រៀបបាននឹងទីក្រុងមួយតូច បានត្រូវស្ថាបនានៅទីសមរភូមិ ដែលជាតឹកតាង នៃ ជោគជ័យរបស់ព្រះអង្គ ទៅលើទ័ពឈ្លានពានចាម ។ ប្រាសាទនេះ សាងឡើង ដើម្បីដាក់ដំបងព្រះខ័ន ដែលជារតនវត្ថុការពារប្រទេស ។ ព្រមទាំង រូបចម្លាក់ព្រះបីតារបស់ព្រះអង្គ មានលំនាំជាព្រះ លោកិស្វរៈ (ព្រះពោធិសត្វ) ដែល ព្រះបាទជ័យវរ្ម័ន ទី៧ មានជំនឿទៅលើដ៏ស៊ុបច្បាស់ ។ នៅជុំវិញរូបចម្លាក់នេះ ព្រះអង្គមានដាក់តំកល់រូបចម្លាក់តំណាងទេវា ជាច្រើន ដោយមានរូបចម្លាក់ព្រះអតីតមហាក្សត្រ ក្នុងនោះផង ។

### ◆ ប្រាសាទនាគព័ន្ធ

ប្រាសាទនេះ បានស្ថាបនាឡើង នៅលើកណ្តាលទំនប់ទឹក ឈ្មោះ ជ័យតតក្កៈ (ទំនប់ព្រះជ័យវរ្ម័ន ឬ បារាយព្រះខ័ន) ។ ប្រាសាទនេះ មានឈ្មោះថា ជ័យស្រី ឬ រាជភ័ព្វ ។ គឺជា ប្រាសាទដែលទ្រដោយផ្កាឈូក តំកល់លើគ្រិស្តមួយ ដែលហ៊ុំព័ទ្ធដោយនាគ ២ ដែលខំព័ទ្ធជុំវិញ ។ លោក បោះសឺលីយ៏ យល់ថា ប្រាសាទនាគព័ន្ធ មានលំនាំស្របនឹងរឿង កោះអនាវតប្តតា ដែលមានទឹកត្រជាក់រហូត ព្រោះទឹកនេះ មិនទទួលពន្លឺព្រះអាទិត្យផ្ទាល់ គឺទទួលពន្លឺដែលជះមកពីទីផ្សេង ។ តាមចក្រសាលសាស្ត្រ ព្រះពុទ្ធសាសនា ទឹកកោះ អនាវតប្តតា នេះ នឹងត្រូវរីងស្ងួត នៅពេលរលាយភពផែនដី ប៉ុណ្ណោះ ។ សីលាចារឹកព្រះខ័ន និយាយថា ព្រះបាទជ័យវរ្ម័ន ទី៧ បានរៀបដាក់តំកល់បូជនីយវត្ថុខាងព្រហ្មញ្ញសាសនាជាច្រើន នៅជុំវិញព្រះពុទ្ធរូប ក្នុងព្រះបំណងចង់ឲ្យបារមីចំរុះ នៃ រតនវត្ថុទាំងនោះ ជួយថែរក្សាប្រទេសជាតិ ។

## ខ. សំណង់ ជាប្រយោជន៍សាធារណៈ

នៅមាត់ផ្លូវ ដែលត្រូវជាបូជនីយវត្ថុដែរ ហើយដែលគួស ចេញពីមហានគរ ឆ្ពោះទៅកាន់ខេត្តនានា ព្រះបាទជ័យវរ្ម័ន ទី៧ បានសង់សាលាសំណាក់ និង មន្ទីរពេទ្យ ជាច្រើន ដោយមានវិហារតូចនៅក្នុងនោះផង ។ សីលាចារឹកតាព្រហ្ម ឲ្យចំនួន ១០២ មន្ទីរពេទ្យ ដែលសង់រាយគ្រប់ទីកន្លែង នៅក្នុងព្រះអធិរាជាណាចក្រ ។ សីលាចារឹកនៅ សាយផុង និយាយថា : "ជម្ងឺរបស់ប្រជារាស្ត្រ ធ្វើឲ្យព្រះអង្គឈឺចាប់ជាងជម្ងឺផ្ទាល់របស់ព្រះអង្គទៅទៀត ព្រោះថា គឺសេចក្តីឈឺចាប់សាធារណជននេះហើយ ជាសេចក្តីឈឺចាប់របស់ព្រះរាជាទាំងឡាយ ពុំមែនសេចក្តីឈឺចាប់ផ្ទាល់ទេ ដែលធ្វើឲ្យព្រះអង្គឈឺចាប់" ។ ចំណែក សាលាសំណាក់ គឺមានចំនួន ១២១ ដែលមានផ្ទះសម្រាប់សំចត ព្រមទាំងចង្ក្រានបាយផង ។ នៅផ្លូវទៅកាន់ ប្រទេសចាម មានសាលានេះចំនួន ៥៧ ។

## គ. សំណង់ អង្គរធំ និង ប្រាសាទបាយ័ន ដែលជាមជ្ឈគ្រិស្តសម្រាប់រាជ្យ

បរិវេណអង្គរធំ មានចំនួន ៣ គ.ម. បួនជ្រុង ដោយមានប្រាសាទបាយ័ន នៅកណ្តាលជាស្នូល ។ ជញ្ជាំងបរិវេណនេះ សង់ដោយថ្មបាយក្រៀម ហើយមានប្រឡាយចង្អូរទឹកទទឹង ១០០ ម. ព័ទ្ធជុំវិញផង ។ បរិវេណនេះ មានទ្វារ ៥ ដ៏ធំ ហើយទ្វារបែរទៅបូព៌ាទិសមាន ២ គឺ ទ្វារមរណៈ និង ទ្វារជ័យ ។ នៅលើដំបូលទ្វារនេះ មានរូបចម្លាក់មុខ ៤ ដែលជាតំណាងព្រះចតុបាល ដែលជាព្រះរាជា នៃ ទិសទាំង ៤ ។ ផ្លូវដែលចេញពីទ្វារ ឆ្លងប្រឡាយទឹក ត្រូវអមដោយរូបយក្ស ដែលទាញនាគជាខ្សែព្រ័ត ។

គឺប្រហែលនៅឆ្នាំ ១២០០ នៅចុងរាជ្យរបស់ព្រះអង្គ ដែល ព្រះបាទជ័យវរ្ម័ន ទី៧ ទ្រង់ស្ថាបនាព្រះមជ្ឈគ្រិស្តប្រចាំរាជ្យរបស់ព្រះអង្គ ដោយមានព្រះបំណងធ្វើសំណង់នេះឲ្យទៅជា តំណាងភ្នំព្រះសុមេរុ នៅលើដី តាមន័យព្រះពុទ្ធសាសនា ។ ក្នុងន័យនេះ ស្របតាម ភ្នំព្រះសុមេរុ ដែលមានកំពូល ៥ ដែលមានព្រះចតុបាយស្ថិតនៅ ដែលមានជួរភ្នំព័ទ្ធជុំវិញជាច្រើនជាន់ ហ៊ុំព័ទ្ធដោយមហានគរ ប្រាសាទបាយ័ន ក៏មានប្រាង្គដែលមានចម្លាក់ព្រះភ័ក្ត្រ ៤ នៅលើកំពូល មានបរិវេណ ធ្វើពីដីបាយក្រៀម និង ប្រឡាយអូរព័ទ្ធជុំវិញដែរ ។ នៅក្នុងប្រាង្គធំ ដែលនៅជាន់ទី ៣ ឥតមានដាក់តំកល់ព្រះទេវរាជា ដែលជាលិង្គព្រះរាជាទេ គឺជារូបចម្លាក់ព្រះពុទ្ធរាជា ក្នុងរូបព្រះពោធិសត្វ អវលោកិតេស្វរៈ ។ នៅជញ្ជាំងថែវ ជាន់ទី ១ មានចម្លាក់ជីវប្រវត្តិព្រះអង្គ និង យុទ្ធនាការដែលផ្តល់នូវជោគជ័យដល់ព្រះអង្គ ។ រីឯ ជាន់ ទី ២ និង ទី ៣ គឺ មានបន្ទប់សម្រាប់តំកល់រូបតំណាងព្រះអតីតមហាក្សត្រខ្មែរ តាំងពីបូរាណកាលមក ព្រមទាំង ព្រះនានា ដែលត្រូវបានទទួលការគោរពបូជា ជាហូរហែរមក ។ ដោយហេតុនេះហើយ បានជាយល់ថា ប្រាសាទបាយ័ន ជាមណ្ឌលគឺបើតាមយោបល់ លោក សឺដេស "ជាលំនៅស្ថាន នៃ ឫទ្ធិអំណាចទូទៅ ដែលមានក្នុងលោក ជាប្រភព នៃ ឫទ្ធិអំណាចនេះ និង ជាខ្សែប្រទល់ដែនផ្សព្វផ្សាយ នៃ ឫទ្ធិអំណាចនេះ" ។ ប្រាសាទបាយ័ន មិនគ្រាន់តែជាសីលាមណ្ឌលប៉ុណ្ណោះទេ គឺថែមទាំងជាសីលាយ័ន្ត្រ ទៅទៀត ។ តាមពិត ពាក្យថា បាយ័ន្ត្រ គឺបានន័យថា បា នៃ យ័ន្ត្រ គឺជាកំពូលយ័ន្ត្រ សម្រាប់ថែរក្សាមហានគររាជសីមា ។ ដូចជា អក្សរនិមួយៗ ដែលនៅក្នុងកន្សែងយ័ន្ត្រ សុទ្ធសឹងតែមានអត្ថន័យសក្តិសិទ្ធិ កន្លែងនិមួយៗ ដែលតំកល់រូបចម្លាក់ព្រះអតីតមហាក្សត្រ និង ទេវានានា ក៏សុទ្ធតែសម្រាប់ជួយបង្កើនឥទ្ធិពលសក្តិសិទ្ធិ ថែរក្សាព្រះអធិរាជាណាចក្រ ដែរ ។ ក្នុងន័យនេះ ព្រះសំណង់នេះ មានន័យជានិមិត្តរូបធំសម្បើមណាស់ ទាំងក្នុងគំនិតផ្តើម ទាំងក្នុងស្ថាបនាផ្ទាល់ ព្រោះជាលើកដំបូងហើយ ក្នុងប្រវត្តិក្បាច់រូបចម្លាក់សំណង់ខ្មែរ ដែលគេឃើញមានរូបព្រះភ័ក្ត្រ ព្រះអវលោកិតេស្វរៈ នៅលើកំពូលប្រាសាទ បើកព្រះនេត្រតម្រង់ទៅគ្រប់ទិស ដើម្បីផ្សព្វផ្សាយនូវ មេត្តាករុណាធម៌ផង ព្រមទាំង ព្រមានកុំឲ្យមារសត្រូវមានបំណងអាក្រក់ ចំពោះព្រះអធិរាជាណាចក្រផង ៕



L'apogée de l'empire angkorien, au début du XIIe siècle : outre les pays khmers, il s'étend sur les territoires actuels de la Thaïlande, du Laos, de la basse Birmanie et du Vietnam méridional.




តទៅលេខក្រោយ

តមកពីទំព័រទី ៨

# កិច្ចប្រជុំគណបក្សប្រជាធិបតេយ្យ...

គណប្រតិភូទាំងអស់នេះនឹងចូលរួមបង្ហាញខ្លួនក្នុងកិច្ចប្រជុំព្រមព្រៀងថ្នាក់រដ្ឋដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៣ និង១៤ ខែមិថុនាឆ្នាំ២០១៤ នៅមជ្ឈមណ្ឌលឌី ស៊ី យូ ឯវ៉សស្ទី។ គោលគំនិតចម្បងនៃកិច្ចប្រជុំព្រមព្រៀងថ្នាក់រដ្ឋនេះគឺដើម្បីចម្រាញ់ជ្រើសរើសបេក្ខជនពីខាងបក្សប្រជាធិបតេយ្យ ដើម្បីឈរជាបេក្ខជន អភិបាលរដ្ឋ មេបញ្ជាការថ្នាក់រដ្ឋ អគ្គមេធាវីប្រចាំរដ្ឋលេខារដ្ឋ និងសវនករ។ ជុំចុងក្រោយនឹងត្រូវបានជ្រើសរើសដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋមដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារទី៩ ខែកញ្ញា ឆ្នាំ២០១៤។

មុននឹងបេក្ខជនអាចឈានដល់ការបង្ហាញខ្លួនក្នុងប្រអប់ឆ្នោតនៃការបោះឆ្នោតបឋមបានបេក្ខជនត្រូវយ៉ាងហោចណាស់ទទួលបានការគាំទ្រ១៥ភាគរយនៃសម្លេងគណប្រតិភូដែលមានវត្តមានក្នុងកិច្ចប្រជុំព្រមព្រៀងថ្នាក់រដ្ឋនោះជាមុនសិន។ បើមិនដូច្នោះទេ ពោលគឺបើមិនបានការគាំទ្រយ៉ាងហោច១៥ភាយរយនោះទេ នោះយុទ្ធនាការរបស់គេចាត់ទុកថាហួសហើយ។

មន្ត្រីជាន់ខ្ពស់របស់រដ្ឋចំនួន២រូបរួមមានលេខារដ្ឋវីលៀម ហ្គាល់វីន និង សវនកររដ្ឋ ស៊ូសានេ បាំផឺ ទាំងពីររូបនេះកំពុងចូលរួមឱ្យគេបោះឆ្នោតគាំទ្រខ្លួនម្តងទៀត ដោយពុំមានគូប្រកួតប្រជែងមកពីខាងបក្សប្រជាធិបតេយ្យនេះទេ។ អភិបាល ដេវ៉ល ផាទ្រិក មិនចូលរួមប្រកួតសារជាថ្មីឡើយ។ ដូចនេះបេក្ខជនដែលនឹងចូលប្រកួតសម្រាប់តំណែងអភិបាលមាន ចូសេហ្វ អាវ៉ែឡុន្ឡ ដូណល បឺរីក្ស ម៉ាសា ខូកលី (បច្ចុប្បន្នជាអគ្គមេធាវី), ស្ទីវគ្រេសម៉ែន (បច្ចុប្បន្នជាហិរញ្ញិក) និង ជូលៀត ខេយ៉ែម។ មេបញ្ជាការប្រចាំរដ្ឋ ធីម មូរ៉េយ បានលាលែងពីតំណែងឆ្នាំមុន និងមិនទាន់ជំនួសដោយនរណាផ្សេងនៅឡើយ។ ដូចនេះ បេក្ខជនសម្រាប់តំណែងនេះ មាន ចេមស៍ អារ៉េណាដឺរ៉ូសា, លីឡែន ឈឹង, ចូណាថាន់ អេដវឺដស៍, ស្ទីវឃីរីហ្គែន និងម៉ៃខ៍ ឡេខ។ ត្បិតអគ្គមេធាវីម៉ាសាខូកលី ចូលរួមប្រកួតប្រជែងតំណែងអភិបាលរដ្ឋម្ល៉ោះហើយម៉ូរ៉ា ហាឡី និងវ៉ារិន ថុលមែន ទាំងពីរប្រកួតប្រជែងយកតំណែងជាអគ្គមេធាវី។ ជាមួយគ្នាដោយសារតែហិរញ្ញិក ស្ទីវ គ្រេសមែនកំពុងតែប្រកួតប្រជែងយកតំណែងអភិបាលផងដែរនោះ ថមខុនរ៉យ, ដិប ហ្គោលបឺជ និង បារី ហ្វាញហ្គោលទាំងបីរូបនេះប្រកួតប្រជែងយកតំណែងហិរញ្ញិក។

ការជ្រើសរើសអ្នកដឹកនាំរបស់យើងគឺជាការទទួលខុសត្រូវដ៏សំខាន់របស់យើងក្នុងនាមជាពលរដ្ឋនៃប្រទេសប្រជាធិបតេយ្យ។ អ្នករាល់គប្បីយកចិត្តទុកដាក់ទៅលើបទបង្ហាញរបស់បេក្ខជននីមួយៗ និងអ្វីដែលពួកគេបាននិយាយ។ អ្នកបោះឆ្នោតដែលបំពេញត្រង់ចំនុចនេះនឹងក្លាយជាម្ចាស់ឆ្នោតដែលជ្រើសរើសអ្នកដឹកនាំដ៏ត្រឹមត្រូវ ដើម្បីដឹកនាំរដ្ឋាភិបាលយើង៕

Continued from page 8

# Democratic Caucus in Lowell

are Joseph Avellone, Donald Berwick, Martha Coakley (the current attorney general), Steve Grossman (the current treasurer) and Juliette Kayyem. Lieutenant Governor Tim Murray resigned last year and was not replaced. The candidates for that office are James Arena-DeRosa, Leland Cheung, Jonathan Edwards, Steve Kerrigan and Mike Lake. Since Attorney General Martha Coakley is running for governor, Maura Healey and Warren Tolman are both running for attorney general. And with Treasurer Steve Grossman also running for governor, Tom Conroy, Deb Goldberg and Barry Finegold are all running for treasurer.

Selecting our leaders is one of the most important responsibilities of a citizen in a Democracy. Everyone should pay attention to what the candidates and their supporters say. Voters who do that will do the best job of electing the right people to lead our government.


## "Help Wanted
## ដំណឹងជ្រើសរើសបុគ្គលិក

Dianna's Hair Salon and Spa is seeking an experience Nail Technician withexperiences of pedicure, manicure, and nail callus.

ដាយអាណា សាឡន និងស្ប៉ា ត្រូវការជាងធ្វើក្រចកមានបទពិសោធន៍ទាំងលាប និងមៀ៉ា

Compensation is communication or salary.

ប្រាក់ខែអាចចរចាបាន

Please call Dianna at 978-495-6652 for interview"

សូមទូរស័ព្ទ 978 495 6652 ដាយអាណាដើម្បីសម្ភាសន៍



LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ — www.lowelleldercare.com

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

សូមហៅលេខទូរស័ព្ទ (978) 596-1111




## តមកទំព័រទី ៣ សាស្ត្រាចារ្យភ្លេងខ្មែរនៅសាកល...

ដែលបានណែនាំលោកឱ្យស្គាល់បណ្ឌិត វីល្មៀម ។ សព្វថ្ងៃនេះ លោកបង្រៀននៅសាលាយូម៉ាសរៀងរាល់ថ្ងៃអង្គារចាប់ពីម៉ោង៥ដល់៩យប់ ។

លោកសង្កេតឃើញថា ៩៩ភាគរយនៃសិស្សដែលរៀនភ្លេងខ្មែរក្នុងថ្នាក់របស់លោកសុទ្ធតែជាកូនសិស្សអាមេរិកាំងមានតិចតួចណាស់ដែលជាអាស៊ី ដូចជា ថៃ និងចិន តែពុំឃើញមានខ្មែរឡើយ ។ ចំណុចនេះលោកក៏អំពាវនាវឱ្យកូនខ្មែរចាប់ផ្តើមយកចិត្តទុកដាក់ផងដែរ ។

បច្ចុប្បន្ននេះ ក្នុងនាមជាសាស្ត្រាចារ្យផងលោកក៏មានជំនួញផ្ទាល់ខ្លួនគឺសំអាងការធីតាសួគិដែលមានអាស័យដ្ឋាន នៅផ្លូវ ២ Pine Street, #A, Lowell, MA 01851 និងអាចទាក់ទងបានតាមលេខទូរស័ព្ទ 978-328-9335 ។

លោកបានចែករំលែកពីគម្រោងដែលលោកគ្រោងនឹងធ្វើនៅពេលខាងមុខមានបីគឺទី១ នឹងបើកបង្រៀនគួរក្រៅម៉ោងសម្រាប់សិស្សទី២ បង្កើតស្ទុយឌីយោថតសម្លេង ទី៣គឺផ្តល់ជូន សេវាកម្មផ្នែកអាពាហ៍ពិពាហ៍មួយឈុតមានសំអាងការថតរូប ថតវីដេអូ កាត់ត មានអាចារ្យ ជាដើមហើយលោកបញ្ជាក់ថាផ្តល់ជូនតម្លៃសមរម្យ និងគុណភាព ៕

## អត្ថប្រយោជន៍នៃគល់ស្លឹកគ្រៃជួយព្យាបាលជម្ងឺ



គល់ស្លឹកគ្រៃមិនត្រឹកតែជាគ្រឿងទេសសម្រាប់ផ្សំអាហាររបស់លោកអ្នកឱ្យកាន់តែមានរសជាតិឆ្ងាញ់ប៉ុណ្ណោះទេ ។ ប៉ុន្តែវាអាចជួយព្យាបាលជម្ងឺរបស់លោកអ្នកមួយចំនួនផងដែរ ។ បើយោងតាមការដកស្រង់ចេញពីគេហទំព័រ Lisa បានឱ្យដឹងដែលថា គល់ស្លឹកគ្រៃអាចជួយព្យាបាលជម្ងឺធីងធោងបានដោយអ្នកគ្រាន់តែយកគល់ស្លឹកគ្រៃចិតជាកង់ៗប្រហែលមួយថ្នាំងដៃ ហើយដាក់ដាំទឹកឱ្យពុះ ហើយលាយជាមួយអំបិលឱ្យច្រើនតាមការគួរ រួចយកមកស្ប៉ាលើដងខ្លួននោះអ្នកនឹងមានអារម្មណ៍ធូរស្រាលជាមិនខាន ។

មួយវិញទៀត ប្រសិនបើអ្នកកើតជម្ងឺផ្តាសាយអ្នកអាចយកគុលស្លឹកគ្រៃទៅដាំទឹកដូចគ្នាប៉ុន្តែអ្នកត្រូវតែចិតលាយជាមួយនឹងខ្ទឹមម្ទាស់វាឱ្យយូរបន្តិច ហើយយកវាមកញ៉ាំក្តៅឧណ្ហៗនោះអ្នកនឹងជាសះស្បើយពីជម្ងឺផ្តាសាយដោយមិនចាំបាច់ចំណាយលុយទៅទិញថ្នាំឡើយ ។ គួរតែនាំគ្នាសាកល្បងវិធីសាស្ត្របុរាណដើម្បីសុខភាពទាំងអស់គ្នា ៕

# វិធី៤ចំណុចសម្រាប់រក្សាសក់របស់អ្នកក្នុងរដូវក្ដៅ



មនុស្សគ្រប់គ្នាសុទ្ធតែស្គាល់ពីព្រះអាទិត្យនៅរដូវក្ដៅ និងឥទ្ធិពលដែលធ្វើឱ្យស្បែករបស់យើងមានមានភាពជ្រីវជ្រួញរបស់វា។ ដោយហេតុនេះពួកគេតែងតែប្រុងប្រយ័ត្នដោយជៀសវាងការត្រូវកំដៅថ្ងៃ។ ប៉ុន្តែអាកាសធាតុក្ដៅ ក៏ជាធាតុដែលអាចបំផ្លាញដល់សក់របស់អ្នកដែរ ។ សូមប្រើនូវគន្លឹះខាងក្រោមនេះ ដើម្បីរក្សាសក់របស់អ្នកឱ្យនៅតែមានសុខភាពល្អនៅរដូវក្ដៅ :

**១.ការពារសក់ពីទឹកមានជាតិប្រៃ និងសារធាតុក្លរ**

មុនពេលដែលលោកអ្នកលោតចូលទៅក្នុងអាងទឹក ឬទឹកសមុទ្រ ដើម្បីហែលលេងនោះ អ្នកត្រូវអនុវត្តនូវ២ទៅ៣ជំហ៊ានដើម្បីការពារសក់របស់អ្នក។ វិធីល្អបំផុតដែលអ្នកអាចធ្វើបានក្នុងការការពារសក់របស់អ្នក មុនពេលហែលទឹក គឺត្រូវធ្វើឱ្យសក់របស់អ្នកសើមជោកជាមុនសិន មុននឹងត្រូវនឹងទឹកអំបិលនៃទឹកសមុទ្រ ឬជាតិក្លរនៃអាងហែលទឹក។ សូមកុំចូលទៅក្នុងអាងហែលទឹកដោយសក់ស្ងួតឱ្យសក់។ បន្ទាប់ពីការហែលទឹក សូមប្រាកដថា អ្នកបានកក់សំអាតសក់របស់អ្នកជាមួយនឹងសាប៊ូកក់ សំអាតសក់ និងផលិតផលសំរាប់សក់ដទៃទៀត ដើម្បីឱ្យប្រាកដថា អ្នកបានសំអាតនូវជាតិក្លរចេញអស់ពីសក់របស់អ្នក។

**២. ការពារសក់ពណ៌ឱ្យផុតពីកំដៅថ្ងៃ**

ដើម្បីការពារពណ៌សក់របស់អ្នក (មិនថាអ្នកលាបពណ៌ ហាយឡាយ ឬអ៊ុតនោះទេ) ឱ្យមានសុវត្ថិភាពពីកំដៅព្រះអាទិត្ររាប់ខែនៅរដូវក្ដៅនោះ គឺមានពីរបីវិធីដែលអ្នកអាចធ្វើបាន។ ទីមួយអ្នកលាបក្រេមការពារកំដៅថ្ងៃមុននឹងចេញទៅត្រូវកំដៅថ្ងៃរយ:ពេលយូរ។ អ្នកប្រហែលជាអាចស្វែងរកបាននូវផលិតផលថែរក្សាសក់ណាមួយ ដើម្បីការពារសក់របស់អ្នកឱ្យផុតពីការខូចខាត ។ប៉ុន្តែពួកវា គឺសុទ្ធតែផ្សំដោយធាតុផ្សំមូលដ្ឋានដូចគ្នា ដូចជាមាន SPF ក៏រិតខ្ពស់។

**៣. ផ្ដល់ដល់សក់នូវជាតិសំនើម និងគ្រឿងការពារកំដៅ**

បើសិនជាអ្នកចង់សក់របស់អ្នកឆាប់លូតលាស់ មានទំងន់ និងមានពន្លឺ វាសំខាន់ណាស់ក្នុងការជៀសឱ្យផុតពីការបំផ្លាញដោយកំដៅ។ មិនថា តែអ្នកចូលចិត្តផ្លុះសំងួតសក់ ឬមូរសក់របស់អ្នកជារៀងរាល់ថ្ងៃ ឬការត្រូវនឹងកំដៅខាងក្រោយយ៉ាងយូរទេ គឺសុទ្ធតែបង្កបញ្ហាដល់សក់របស់អ្នក។ បើសិនជាអ្នកសង្កេតឃើញថាសក់របស់អ្នកកាន់តែស្ងួតជាងធម្មតា សូមបន្ថែមការយកចិត្តទុកដាក់ក្នុងការបន្ថែមជាតិសំណើមដល់វាឱ្យបានច្រើនឡើង។ មធ្យោបាយងាយស្រួលបំផុតគឺប្រើក្រែមបន្ទន់សក់។ អ្នកក៏អាចប្រើសាប៊ូកក់ដែលមានទាំងក្រែមបន្ទប់សក់ក្នុងជាស្រេចក៏បាន។ ប៉ុន្តែបើអ្នកឃើញថា សក់របស់អ្នកនៅតែមានភាពស្ងួតនៅខាងចុង សូមបន្ថែមនូវក្រែមបន្ទន់សក់លើវានៅតែផ្នែកខាងចុងបន្ថែមទៀត។ បើសិនជាអ្នកមានសក់បែកចុងសូមធ្វើការកាត់តំរឹមវាជារៀងរាល់៦ទៅ៨សប្ដាហ៍ ដើម្បីកាត់ចោលនូវផ្នែកដែលខូចនោះ។

**៤. បញ្ឈប់ការបែកញើសជោកសក់**

នៅពេលដែលអ្នកស្ថិតនៅខាងក្រៅនៅរដូវក្ដៅសក់របស់អ្នកនឹងបែកញើសយ៉ាងច្រើន។ វាមានវិធីមួយចំនួនដែលអ្នកអាចប្រើបានដើម្បីការពារសក់របស់អ្នកនៅពេលមានបញ្ហានេះ។ ទីមួយសូមប្រើប្រាស់តែសំភារៈណាដែលមានភាពឃឹតសំរាប់តុបតែងសក់របស់អ្នក។ បើសិនជាអ្នកប្រើប្រភេទផ្សេងនោះវានឹងធ្វើឱ្យសក់របស់អ្នកផុយ ស្រួយ នឹងងាយដាច់។ បន្ថែមលើនេះ ដើម្បីជៀសវាងប្រតិកម្មផ្សេងៗលើស្បែក សូមអ្នកធ្វើសក់របស់ចេញផុតពីផ្ទៃមុខរបស់អ្នក។ ញើសនៅនឹងសក់ងាយតោងជាប់នឹងថ្ងាស ឬផ្ទាល់ដែលបង្កជាមុន ឬរោកសើស្បែកផ្សេងៗណាស់៕


May May BEAUTY
ហាងកែសម្ផស្ស ម៉ីម៉ី

120 Cambridge St, Suite 6
Burlington, MA 01803 | 781-272-1389

**យើងខ្ញុំមានបទពិសោធន៍13 មកហើយ ផ្ដល់ជូន**
- ការបញ្ចុះតម្លៃគម្រប់5ឆ្នាំ
- បញ្ចុះតម្លៃ20% សម្រាប់ផលិតផថែរក្សាស្បែក
- បញ្ចុះតម្លៃ20% សម្រាប់ការពិនិត្យម្ដង
- បញ្ចុះតម្លៃ10% សម្រាប់ការពិនិត្យពី5ទៅ10ដង ផុតកំណត់ថ្ងៃទី 30កក្កដា2014



យើងខ្ញុំអាចជួយលោកអ្នកក្នុងការបញ្ចៀសស្បែកជ្រីវជ្រួញ មុន ជាំ និងស្នាម ព្រមទាំងប្រភេទស្បែកមានខ្លាញ់ស្ងួត និងស្បែកងាយរងនូវការប៉ះទង្គិចផ្សេងៗ។ យើងខ្ញុំធានាផ្ដល់ជូននូវសេវាដោយការយកចិត្តទុកដាក់ និងបម្រើដោយអស់ពីចិត្ត។ យើងខ្ញុំបម្រើផ្ដល់ជូនលោកអ្នកនូវផលិតផលសម្រាប់ស្បែកមុខដែលមានគុណភាពនាំចូលពីអឺរ៉ុប និងសម្ភារ:ទំនើប។ សូមមកទទួលសេវាថែទាំស្បែក និងសម្ផស្សពីហាងយើខ្ញុំដើម្បីរក្សានូវភាពស្រស់ស្អាត និងវ័យក្មេង។



ពេទ្យធ្មេញសំរាប់គ្រួសារ
Caring Dental For ALL Ages




FREE
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 07/27/13

"EXCLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 07/27/13

COMPLETE ផ្ដល់គ្រប់សេវាកម្ម Services
- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្រ្ចាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Convenient LOCATION
Next to Bank of America on Chelmsford Street




Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស្ទួរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ប៉ានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនាថ្ងៃនេះ
724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles–Dental.com

# Red Rose

ភោជនីយដ្ឋាន RESTAURANT

ក្លាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិន
ខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm







* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400









## Help Wanted

### Pailin Dental Center:
### Chien Yu Hsu D. M.D, M.A.C.D

ដំណឹងជ្រើសរើសបុគ្គលិក
ទន្តបណ្ឌិត និងមន្ទីរពេទ្យធ្មេញយើងខ្ញុំត្រូវការ
ជ្រើសរើសបុគ្គលិកដូចខាងក្រោម៖

- Front Desk
- Dental Assistant
  Khmer/English

ផ្តល់ជូនតម្លៃម៉ោង $10/h

Tel: 978-453-7800

## Help Wanted

### Tep Thida Khmer Restaurant

ដំណឹងជ្រើសរើសបុគ្គលិក
ភោជនីយដ្ឋានទេពធីតាខ្មែរ ត្រូវការជ្រើសរើស
បុគ្គលិកដូចខាងក្រោម៖

- Chief
- Server
- Manager

Well-trained applicants will be appreciated!

Tel: 978-453-1694

## AccuCare

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

### ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

To be eligibled for GAFC you must:
-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
-មាស់ហែល់ស្តង់ដា (eligible for Masshealth Standard)
-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
-ត្រូវបានវាយតំលៃផ្នែកសុខភាព នឹងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

### ផលប្រយោជន៍ទទួលបាន :

Benefits you will get:
-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
-វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:



អ៊ុក តុលាយុទ្ធ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852



ពិន ឆាវ៉ាន់ លីន រីវៀរ បូស្តុន
Chhavan Pin: Lynn, Revere, Boston
Tel:(617)783-7177, Fax: (617) 783-7188
Office: 214 Lincoln St., Suite 200. Allston, MA 02134



# ជោគជតារាសីលោកអ្នក ទាំង១២ប្រចាំឆ្នាំរោង

## ឆ្នាំជូត

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗ នាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញ យ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀប ដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

## ឆ្នាំឆ្លូវ

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

## ឆ្នាំខាល

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នា ជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

## ឆ្នាំថោះ

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

## ឆ្នាំរោង

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបាន ដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

## ឆ្នាំម្សាញ់

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះ សូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះ ប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

## ឆ្នាំមមី

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

## ឆ្នាំមមែ

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិ និងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើតែហាមកុំជួញដូរផ្លូវឆ្ងាយ ប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

## ឆ្នាំវក

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

## ឆ្នាំរកា

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្អុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

## ឆ្នាំច

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

## ឆ្នាំកុរ

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះសុទ្ធតែផ្តល់នូវអត្ថប្រយោជន៍ គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នា បើនៅឆ្ងាយ ៕



# វិធីបន្ថយទម្ងន់ ដូចក្តីប្រាថ្នា

សកម្មភាពការបន្ថយទម្ងន់របស់ស្រ្តីសម័យនេះ ជំហានដំបូងដែលមនុស្សគ្រប់រូបនឹកដល់នោះ គឺការបង្អត់អាហារ ឬថាការគ្រប់គ្រងទម្ងន់នោះឯង ។ ទោះបីជាវាជួយឱ្យយើងកាត់បន្ថយទម្ងន់បានក៏ពិតមែន តែមិនយូរប៉ុន្មានវានឹងត្រឡប់ឡើងមកមានទម្ងន់ដូចដើមវិញ ។

ក្រុមអ្នកជំនាញផ្នែកចំណីអាហារឈានមុខគេ មួយបានណែនាំពីវិធីបែបងាយៗដើម្បីជួយកាត់បន្ថយទម្ងន់លើសនោះ គឺការបម្រែបម្រួលសកម្មភាពការទទួលទានដោយអ្នកមិនត្រូវបណ្តោយឱ្យឃ្លានតទៅទៀតឡើយ ។

**-ហាមផឹកទឹកក្រូច :** ទឹកក្រូចពោរពេញទៅដោយ ថាមពលជាគីឡូនជូន និងជាតិស្ករប្រមាណ៧ស្លាបព្រា កាហ្វេក្នុងមួយកំប៉ុង ។ បើតាមលទ្ធផលពិសោធន៏គេបានរកឃើញថា ទឹកក្រូចគឺជាអ្នកភ្នោចឱ្យឡើងទម្ងន់ ព្រោះប្រភេទស្ករនៅក្នុងទឹកក្រូចមានអ័រម៉ូនគ្រប់គ្រងចំណង់ភេសជ្ជៈធ្វើឱ្យយើងចង់ផឹកវាកាន់តែច្រើនឡើង ។

**-ហ្វឹកហាត់ធ្វើការងារផ្ទះ :** ការបោសច្រាស់ ឬជូតសម្អាត បូមធូលីប្រមាណ៣ម៉ោង ក្នុងមួយសប្តាហ៍វាអាចជួយដុតបំផ្លាញថាមពលរហូតដល់ទៅ៣០០០គីឡូជូនធ្វើឱ្យទម្ងន់ថយចុះបាន៥គីឡូក្រាមតែក្នុងរយៈពេល១១ខែ ។ ចំណែកការដាំស្លវិញ វាអាចជួយដុតបំផ្លាញថាមពលបានប្រមាណ៥០០គីឡូជូនក្នុងរយៈពេល៣០នាទី ។ ដូច្នេះប្រសិនបើធ្វើអាហាររាល់ក្បាលព្រលប់អ្នកនឹងអាចកាត់បន្ថយបាន៥គីឡូក្រាមក្នុងរយៈពេល១០ខែ ។

**-ទទួលទានក្រូចថ្លុងឱ្យបានច្រើន :** បើតាមការពិសោធន៏នៅក្នុងសហរដ្ឋអាមេរិក រយៈពេល៣ខែ គេឃើញថាអ្នកដែលទទួលទានក្រូចថ្លុង៣ដងក្នុងមួយថ្ងៃអាចកាត់បន្ថយទម្ងន់ជាមធ្យមបានប្រមាណ១គីឡូក្រាម ដែលអ្នកខ្លះអាចកាត់បន្ថយបានច្រើនរហូតដល់៥គីឡូក្រាមឯណោះ ។ ដូច្នេះក្រូចថ្លុងវាជាផ្លែឈើមួយស្ថិតនៅក្នុងគម្រោងកាត់បន្ថយទម្ងន់បានយ៉ាងមានប្រសិទ្ធភាព ព្រោះវាជួយឱ្យយើងមិនសូវឃ្លានអាហារ ។

**- ឈប់សម្រាកឱ្យបានគ្រប់គ្រាន់ :** មនុស្សដែលទទួលទានដំណេកមិនលក់អាចធ្វើឱ្យទម្ងន់ខ្លួនកើនឡើង បើតាមលទ្ធផលពិសោធន៏គេបានរកឃើញថា អ្នកដែលទទួលទានដំណេកមិនគ្រប់គ្រាន់គេនឹងកើនការទទួលទានឡើង១២០០គីឡូជូនក្នុងមួយថ្ងៃ ។ ដូច្នេះការទទួលទានដំណេកប្រមាណ៨ម៉ោងក្នុងរយៈពេល១យប់ វាជួយឱ្យអ្នកកាត់បន្ថយទម្ងន់បាន៥គីឡូក្រាមក្នុងរយៈពេល៤ខែ ៕






# អាថិកំបាំងធ្វើឱ្យស្បែកស្អាត



**១.**ព្យាយាមទទួលទានទឹកក្នុងមួយថ្ងៃឱ្យបាន៨កែវ ព្រោះជាតិទឹកវាជួយសម្រួលប្រព័ន្ធទាំងអស់នៅក្នុងរាងកាយឱ្យមានដំណើរល្អ ។ ដូច្នេះធ្វើយ៉ាងណាព្យាយាមទទួលទានទឹកឱ្យបាន៨កែវក្នុងមួយថ្ងៃ ដើម្បីជួយរក្សាសំណើមដល់ស្បែក ព្រមទាំងជួយកម្ចាត់សារជាតិពុលពីរាងកាយបានទៀតផង ។

**២.**ជ្រើសរើសទទួលទានបន្លែផ្លែឈើ និងត្រីឱ្យបានច្រើនជាងគេ ពីព្រោះវាមានសារសំខាន់ចំពោះសុខភាពស្បែក ។

**៣.**ឡេការពារកម្តៅថ្ងៃនៅក្នុងកម្តៅថ្ងៃមានផលអាក្រក់ជាច្រើនបំផ្លាញដល់ស្បែកក្នុងនោះមិន ថាកាំរស្មី UVA UVB ដូច្នេះទោះបីស្ថិតក្នុងស្ថានភាពអាកាសធាតុបែបណាក៏ដោយ គួរជ្រើសរើសប្រើឡេការពារកម្តៅថ្ងៃមានកម្រិត spf 30 ព្រមទាំងចៀសវាងកម្តៅចាប់ពីម៉ោង១១:០០-១៥:០០ ព្រោះអំឡុងពេលនេះកម្តៅថ្ងៃនឹងបំផ្លាញស្បែកអ្នកបាន ៕

# ខ្មែរអ្នកជាតិនិយម

**តពីលេខមុន**

សីហនុ ខ្លាំងឡើងៗ ដោយចោទប្រកាន់ថា ទ្រង់បានលើកប្រទេសកម្ពុជា ដោយដៃទាំងគូទៅឱ្យបារាំង ដោយឥតបានទទួលមកវិញនូវកម្រៃអ្វីបន្តិចដល់ប្រជាជាតិឡើយ សូម្បីតែទឹកដីខ្មែរដែលបារាំងកាត់ទៅឱ្យសៀមតាមសន្ធិសញ្ញាតូក្យូពីឆ្នាំ១៩៤១នោះ ក៏ស្ថិតនៅក្រោមការត្រួតត្រារបស់សៀមដដែល ។ ឯ ហូជីមិញ វិញ កាត់បានទទួលកម្រៃចំណេញពីបារាំងយ៉ាងសន្ធឹកសន្ធាប់ដោយសារកម្លាំងតស៊ូគ្រប់បែបយ៉ាង ។ ហេតុនេះស្ដេច សីហនុ និងសម្ដេច មុនីរ៉េត យល់ឃើញថា ត្រូវតែធ្វើដំណើរទៅប្រទេសបារាំង ដើម្បីបង្ហាញចំណោទទាំងអស់ដែលមានទៅឱ្យរដ្ឋាភិបាលបារាំងគិតគូរមើល ។




នៅថ្ងៃទី១២ ឧសភា ១៩៤៦ ស្ដេច សីហនុ បានធ្វើដំណើរទៅដល់ប្រទេសបារាំង ចំពេលគេកំពុងបោះឆ្នោតជ្រើសរើសប្រធានាធិបតី ។ ពេលនោះ ដឺហ្គោលបានលាឈប់ពីតំណែងទុកឱ្យ ហ្វេរិក គូវ៉ាន់ កាន់ការជំនួស ។ ទ្រង់បានជួបសន្ទនាជាមួយហ្វេរិក គូវ៉ាន់ ដែរ តែឥតបានជាការអ្វីឡើយ ។ ឆ្នាំ១៩៤៦នេះហើយ ដែលជាឆ្នាំទំនាស់គ្នារវាងរដ្ឋាភិបាល មុនីរ៉េត និងក្រុមបញ្ញវន្តជាតិនិយម សឺន ង៉ុកថាន់ ។ ឆ្លៀតឱកាសនេះ ស្ដេច សីហនុ ដែលថា ស្អប់ខ្ពើមលោក សឺន ង៉ុកថាន់ នោះ ក្នុងគោលបំណងផ្ដួលរំលំមុនីរ៉េត និងក្រុមបញ្ញវន្តជាតិនិយម សឺន ង៉ុកថាន់ ។ ឆ្លៀតឱកាសនេះ ស្ដេច សីហនុ ដែលថា ស្អប់ខ្ពើមលោក សឺន ង៉ុកថាន់ នោះ ក៏ស្រាប់តែឆាក់ឆៅងាកបែរមករកពួក សឺន ង៉ុកថាន់ និយមទៅវិញ ក្នុងគោលបំណងផ្ដួលរំលំ មុនីរ៉េត ជាឪពុកមារឱ្យដួលបះជើងច្រោងតែម្ដង ។ ដូច្នេះរដ្ឋាភិបាល មុនីរ៉េត កាន់តែបាត់បង់ប្រជាប្រិយភាពត្បិតជារបបផ្ដាច់ការផង ខ្វះស្ថិរភាពផង ហើយថែមទាំងជារដ្ឋាភិបាលទ្របាតជើងបារាំងទៅវិញ ។ គ្រានោះ ក្រុមអ្នកចេះដឹងបានឱ្យឈ្មោះរដ្ឋាភិបាលសម្ដេច មុនីរ៉េត ថា ជារដ្ឋាភិបាលទឹងមោង ខ្លះថាជាអាយ៉ងរបស់បារាំង ព្រោះថាក្រុមមុនីរ៉េតសុទ្ធតែជាមនុស្សល្ងីល្ងើមិនសូវដឹងខុសត្រូវរាក់ជ្រៅអ្វីទេ ។

ដល់ឃើញដូច្នោះ បារាំងក៏ចាប់គិតគូរប្ដូររដ្ឋាភិបាល ដោយជ្រើសរើសតែមនុស្សដែលស្រលាញ់ងាប់រស់ និងគោរពបារាំង គឺព្រះអង្គម្ចាស់ នរិន្ទដេត ។ ដោយមានអ្នករាជការ និងអ្នកវ៉ាយអែបសុីអបខ្លះនៅតាមខេត្តជួយគាំទ្រផង នរិន្ទដេត ក៏ខំប្រឹងប្រែងយ៉ាងសកម្មបង្កើតគណបក្សនយោបាយមួយឈ្មោះ "គណបក្សសេរីភាព"ដែលស្នើឱ្យមានរបបរាជាធិបតេយ្យគោរពរដ្ឋធម្មនុញ្ញ ហើយដែលអាចអនុវត្តបន្តិចម្ដងៗទៅកាន់លទ្ធិប្រជាធិបតេយ្យក្រោមការដឹកនាំ និងឧបត្ថម្ភរបស់បារាំង ។ បារាំងពេញចិត្តយ៉ាងខ្លាំង ចំពោះខ្សែបន្ទាត់នយោបាយនៃគណបក្សសេរីភាពនេះ ហើយបានជួយឧបត្ថម្ភយ៉ាងពេញបន្ទុក ។

### គណបក្ស និងរដ្ឋធម្មនុញ្ញខ្មែរ

ក្រោយពីការថ្វាយយោបល់របស់ក្រុមអ្នកជាតិនិយម សឺន ង៉ុកថាន់ និងមុនចេញព្រះរាជដំណើរទៅប្រទេសបារាំងជាលើកទី២ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៤៦ នោះ ព្រះករុណា សីហនុ បានឱ្យដឹងថា នៅពេលខាងមុខដ៏ខ្លីព្រះអង្គ និងលុបចោលនូវរបបរាជាធិបតេយ្យផ្ដាច់ការ ហើយសេចក្ដីព្រាងរដ្ឋធម្មនុញ្ញមួយនឹងត្រូវដាក់ឱ្យរដ្ឋសភាបណ្ដោះអាសន្នពិនិត្យ ។ នៅគ្រប់ភូមិក្នុងរាជាណាចក្រទាំងមូលអ្នកមានសិទ្ធិបោះឆ្នោតនឹងត្រូវធ្វើការជ្រើសរើសរកអ្នកតំណាងនៅក្នុងរដ្ឋសភាបណ្ដោះអាសន្នដោយវិធីបោះឆ្នោតមិនចំពោះ ។

រាជបញ្ញត្តិមួយចុះថ្ងៃទី៩ មេសា ១៩៤៦ បានបើកឱ្យមានសេរីភាពក្នុងការបង្កើតសមាគមសេរីភាពក្នុងការប្រជុំ និងឃោសនាក្នុងកម្លុង ពេលរៀបចំការបោះឆ្នោត ។ ក្រោយពីការប្រកាសឱ្យមានសេរីភាពនោះមកមានគណបក្សធំៗ៣បានកើតឡើងគឺៈ

**១-គណបក្សសេរីភាព** ដឹកនាំដោយព្រះអង្គម្ចាស់ នរិន្ទដេត ។

**២-គណបក្សជឿនលឿន** ដឹកនាំដោយអ្នកអម្ចាស់នរោត្តម ម៉ុង តាណា ដែលជាមាម្នាក់ទៀតរបស់ស្ដេចសីហនុ ដែលចង់ឱ្យមានរបបរាជាធិបតេយ្យគោរពរដ្ឋធម្មនុញ្ញ ដូចគណបក្សសេរីភាពដែរ ។

**៣-គណបក្សប្រជាធិបតេយ្យ** ក្រោមការដឹកនាំរបស់ទ្រង់ សុីសុវត្ថិ យុត្តិវង្ស ដែលចង់បានរបបប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ មានរដ្ឋសភាជាធំ ហើយជាពិសេសទៅទៀត ត្រូវធ្វើតស៊ូតាមផ្លូវនយោបាយ ដើម្បីទាមទារយកឯករាជ្យពេញទីពីបារាំង ។ គណបក្សប្រជាធិបតេយ្យនេះ បានទទួលការគាំទ្រពីក្រុមអ្នកជាតិនិយមទាំងអស់ ព្រមទាំងទទួលការឧបត្ថម្ភយ៉ាងមាំពីសំណាក់ព្រះសង្ឃ ដែលឥតត្រូវការឱ្យបារាំង

**តទៅលេខក្រោយ**



# បំបាត់អាចម៍រុយ ដោយផ្លែទំពាំងបាយជូ



កាលណាគេនិយាយពីសោភ័ណភាពស្បែកនោះ គោលដៅចម្បងពិតជាគេចមិនផុតពីសុភាពស្ត្រី ព្រោះថារឿងសម្រស់វាហាក់ដូចជាផ្សារភ្ជាប់ទៅនឹងជីវិតបច្ចុប្បន្នដែលជាយុគមួយកំពុងពេញនិយមក្នុងការប្រកួតប្រជែងសម្ផស្សគ្នានោះ ។

សម្រាប់រឿងស្នាមជ្រីវជ្រួញ ឬក៏ស្នាមអាចម៍រុយគ្មាននរណា ម្នាក់មានបំណងប្រាថ្នាឱ្យវាកើតមាននៅលើមុខរបស់ខ្លួននោះឡើយ ព្រោះវាមិនមែនជារឿងដែលគួរត្រេកត្រអាល ។ ដូច្នេះយើងនាំគ្នាក្រឡេកមកមើលពីភាពសំខាន់ក្នុងការស្វែងរករូបមន្តពិសេស ដើម្បីលុបបំបាត់ ចំណុចអាចម៍រុយនៅលើមុខអ្នកដូចខាងក្រោមនេះ :

**-វិធីនៃរូបមន្តពិសេសនេះអាចចាប់ផ្តើមបានដោយខ្លួនឯងគឺ :**

ការត្រៀមទំពាំងបាយជូរពណ៌បៃតងពី៤-៥ផ្លែ ទឹកដោះគោជូរ២ ស្លាបព្រាកាហ្វេ និងទឹកឃ្មុំសុទ្ធមួយស្លាបព្រាកាហ្វេ ។ បន្ទាប់មក



យកទំពាំងបាយជូរបៃតងមកពុះយកគ្រាប់ចេញ រួចហើយយកទៅដាក់ក្នុងម៉ាស៊ីនកិនឱ្យល្អិតលាយជាមួយទឹកដោះគោជូរ ទឹកឃ្មុំ រួចហើយ ក្រឡុកចូលគ្នាឱ្យសព្វ ។

បន្ទាប់ពីនោះនាំយកមកបំពោកលើផ្ទៃមុខដោយទុកសំងិលចោលរយៈពេល២០នាទី ទើបលាងជម្រះដោយប្រើទឹកក្តៅឧណ្ហៗ រូបមន្តនេះអាចធ្វើបានញឹកញាប់រៀងរាល់២-៣សប្តាហ៍ជាប់បន្តគ្នា ដែលយ៉ាងហោចណាស់ទាមទារឱ្យប្រើរយៈពេល១៥ថ្ងៃ ទើបឃើញលទ្ធផល ។ រូបមន្តពិសេសៗបែបនេះ សុភាពស្ត្រីទាំងឡាយមិនគួរមើលរំលងនោះឡើយ ។ ដូច្នេះចាប់តាំងពីពេលនេះតទៅសង្ឃឹមថា អ្នកនឹងយក រូបមន្តនេះប្រើប្រាស់ដើម្បីសម្រស់ផ្ទៃមុខជាក់ជាមិនខាន ៕


# ហាងជួសជុលរថយន្តឡូវែល
## Lowell Automatic Transmission

**Winter special $19.95**
ពិសេសសម្រាប់រដូវរងារ

- ថ្នអាគុយ/តេស្តប្រព័ន្ធបញ្ចូលភ្លើង
- ពិនិត្យអង់ទីហ្វ្រីស
- ពិនិត្យហ្វ្រាំងទាំងមូល
- ជម្រះប្រេងគ្រប់ប្រភេទ
- បង្វិលកង់រថយន្តឲ្យស្មើ

**ពិនិត្យ**

- បន្ទះជូតកញ្ចក់ឡាន
- ប្រព័ន្ធកំដៅ/ត្រជាក់
- បែលធ៍ / ហូស (Belts & Hoses)
- អំពូលភ្លើងខាងក្រៅទាំងអស់

**ដូរប្រេងតម្លៃត្រឹមតែបន្ថែម $9.95**

- កែតុនអំពូលភ្លើងខាងមុខ
  តម្លៃ. $79.95
  បញ្ចុះតម្លៃ $49.95
- ប្រគេនអំពូលបំភ្លឺសម្រាប់
  Vehicle Flush Options
  ‣ Transmission ‣ Power Steering
  ‣ Brake System ‣ Fuel System

202 Chelmsford Street. Lowell, MA 01851
ប្រព័ន្ធភ្លើង ជួសជុលទូទៅ សំបក និងតួខ្លួនឡាន
Phone: 978-458-4775|978-453-8621|Fax: 978-454-4599

# ហាងលក់រថយន្តផ្លូវឆឹមស្ហ៊ីត
## Chelmsford Street Auto Sales

202 Chelmsford St. Lowell, MA 01851
Tel: 978-452-9154 | www.CStreetAuto.com
សូមអញ្ជើញមកទស្សនាបន្ទប់តាំងបង្ហាញរថយន្តទើបកែថ្មីដែលមានច្រើនជាង១០០គ្រឿងនៃរថយន្តដែលប្រើហើយ
យើងខ្ញុំមានមោទនភាពដែលបានបម្រើសហគមន៍ឡូវែលអស់រយៈពេល៦ឆ្នាំមកហើយ
សូមចូលកាន់គេហទំព័រយើងខ្ញុំ ដើម្បីទទួលបានជម្រើសថ្មីៗ www.CStreetAuto.com





# រមណីយដ្ឋានកោះមរកត "កោះពស់" ក្លាយជាតំបន់ទេសចរណ៍ "មាស"

ផ្សាយក្នុងផ្នែកទេសចរណ៍ ដោយ កាល ពី១ឆ្នាំមុន បើកមើល ១.៧៥៨ ដង

កាលពីប៉ុន្មានឆ្នាំមុន កោះពស់គ្រាន់តែជាកោះមួយសម្រាប់អ្នកទេសចរផ្សងព្រេងទៅលេងកម្សាន្តជាមួយធម្មជាតិ ឬ ស្ងួចត្រី និងមុជមើលផ្កាថ្មប៉ុណ្ណោះ ប៉ុន្តែសព្វថ្ងៃនេះកោះពស់បានក្លាយទៅជាទីគោលដៅទេសចរណ៍ "មាស" មួយនៅតំបន់អាស៊ីអាគ្នេយ៍ហើយ ដែលគេរំពឹងថា ជាទេសចរណ៍ធម្មជាតិដ៏អស្ចារ្យនៅដែនសមុទ្រ ក្រុងព្រះសីហនុ និងនៅក្នុងតំបន់ ។ កោះមរកតជាឈ្មោះរមណីយដ្ឋានមួយបង្កើតឡើងនៅលើកោះពស់ដែលពោរពេញទៅដោយសោភណភាពបែបធម្មជាតិពិត។ ។ គេគ្រាន់តែធ្វើដំណើរឆ្លងស្ពានថ្មមួយសាងសង់ថ្មីភ្ជាប់ទីក្រុងព្រះសីហនុទៅកោះតែ ៤ ឬ ៥ នាទីប៉ុណ្ណោះ ។

កោះមរកតមានអគារស្នាក់នៅប្រណីត។ ចំនួន ៣៦ ខ្នង សង់ តាមបណ្ដោយឆ្នេរសមុទ្រ នៅលើផ្ទៃដីទំហំ ៤៥០ ទៅ ៥៧០ ម៉ែត្រការ៉េ ។ ផ្ទះនីមួយៗមាន បន្ទប់ដេកពី ៣ ទៅ ៥ បន្ទប់ មានចំណតរថយន្តសម្រាប់រថយន្តពីរគ្រឿង និងសង់តាមលំនាំបស្ចិមប្រទេសជឿនលឿន មានបន្ទប់ទឹកបំពាក់ដោយសម្ភារៈទំនើបៗ មានរានហាលមានអាងហែលទឹកដែលមើលឃើញសមុទ្រល្វឹងល្វើយ ។



ថ្មីៗនេះមានគម្រោងអភិវឌ្ឍតាមបែបអន្តរជាតិដោយមានក្រុមជំនាញៗមកធ្វើការ ព្រមជាមួយគម្រោងបង្កើតសហគមន៍ទេសចរណ៍ និងលំនៅស្ថានឯកជនយ៉ាងល្អប្រណីតដែលស្ថិតនៅលើកោះដ៏ស្រស់ត្រកាលមួយរបស់កម្ពុជា គឺកោះពស់ដែលមានផ្ទៃក្រឡាប្រមាណជា ១.១៦៦.០៦១ម៉ែត្រការ៉េ ។ នេះជាគម្រោងអភិវឌ្ឍសំខាន់បំផុតមួយរបៀបឧស្សាហកម្មទេសចរណ៍ថ្មី តាមបណ្ដោយឆ្នេរប្រទេសកម្ពុជា។

កោះមរកតមានទីតាំងស្ថិតនៅក្នុងសមុទ្រនៃក្រុងព្រះសីហនុក្នុងចម្ងាយ៩៥០ម៉ែត្រត្រង់ភាគខាងត្បូង ហើយកោះមរកតមានគោលបំណងនឹងអភិវឌ្ឍឱ្យមានស្តង់ដារអន្តរជាតិខ្ពស់បំផុត រួមជាមួយស្ពានសម្រាប់ឆ្លងកាត់មន្ទីរពេទ្យលំនៅស្ថានឯកជន និងបង្កឱ្យមានភាពងាយស្រួលក្នុងវិស័យពាណិជ្ជកម្ម និងការសម្រាកវិស្សមកាលបូករួមជាមួយនឹងសម្រស់ឆ្នេរស្អាតដាច់គេរបស់ប្រទេសយើងផងដែរ។ ដំណាក់កាលដំបូងមានការសាងសង់ផ្ទះវីឡាដ៏ប្រណីតចំនួន ៣៦ នៅប្របនឹងមាត់ឆ្នេរ និងផ្ទះល្វែងចំនួន ១៩៨ ដែលឥឡូវនេះកំពុងដាក់លក់តាមគេហទំព័រ ww.morakotisland.com ៕



